ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា
គណៈសង្ឃនាយកទាំងពីរគណៈ

# គោលនយោបាយវត្តសង្គហកុមារ




សម្រាប់

វត្តអារាមព្រះពុទ្ធសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា

ព.ស ២៥៦៤ រក្សាសិទ្ធិ គ.ស ២០២០

# មាតិកា

ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គោលនយោបាយវត្តសង្គហកុមារ ..... ៥
និវេទនកថាគណៈធម្មយុត្តិកនិកាយ ..... ៦
និវេទនកថាគណៈមហានិកាយ ..... ៧
សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងគ្រូឧទ្ទេសវត្តសង្គហកុមារនៅកម្ពុជា ..... ៨
ជំពូក ១៖ គោលនយោបាយវត្តសង្គហកុមារ ..... ១១
ជំពូគ ២៖ កម្មវិធីវត្តសង្គហកុមារ ..... ២២
១. សេចក្តីផ្តើម ..... ២២
២. សាវតារ និងស្ថានភាព ..... ២៤
៣. កម្មវិធី ..... ២៦
៣.១. សមាសធាតុកម្មវិធី ..... ២៧
៣.១.១. ការអនុវត្តគោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម ..... ២៧
៣.១.២. ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ..... ២៨
៣.១.៣. ការពិនិត្យតាមដាន និងការវាយតម្លៃ ..... ៣១
៣.១.៤. កត្តាសំខាន់ៗ ចំពោះជោគជ័យរបស់កម្មវិធី ..... ៣៣
៤. ផែនការអនុវត្ត ..... ៣៤
៥. ថវិកា ..... ៣៥
៦. ឧបសម្ព័ន្ធ ..... ៣៧
ឧបសម្ព័ន្ធ ១៖ ក្រមសីលធម៌កិច្ចការពារកុមារតាមវត្តអារាម ..... ៣៧
ឧបសម្ព័ន្ធ ២៖ យន្តការរាយការណ៍ករណី ..... ៣៩
ឧបសម្ព័ន្ធ ៣៖ ទម្រង់រាយការណ៍ករណី ..... ៤០
ឧបសម្ព័ន្ធ ៤៖ ទម្រង់របាយការណ៍លទ្ធផលកម្មវិធីវត្តសង្គហកុមារ ..... ៤២
ឧបសម្ព័ន្ធ ៥៖ តារាងតក្កភាពកម្មវិធី ..... ៤៣
ឧបសម្ព័ន្ធ ៦៖ ផែនការអនុវត្តកម្មវិធីរយៈពេល៣ឆ្នាំ ..... ៤៦
ឧបសម្ព័ន្ធ ៧៖ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការផ្តល់វិញ្ញាបនបត្រ និងមេដាយសម្រាប់វត្តសង្គហកុមារ ..... ៤៨
ឧបសម្ព័ន្ធ ៨៖ ការគ្រប់គ្រងហានិភ័យ ..... ៥០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ......១០/២០..........ក.ធ.សភាគ

# សេចក្តីណែនាំ
## បង្គំទូលថ្វាយ ប្រគេន និងជម្រាបមក
## សម្តេច ព្រះរាជាគណៈ ព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការ និងព្រះសង្ឃគ្រប់ព្រះអង្គ
## លោក លោកស្រី ប្រធានមន្ទីរធម្មការ និងសាសនា គ្រប់រាជធានីខេត្ត

**យោង៖** ប្រកាសលេខ ១៦៣/១៨ ក.ធ.ស.ប្រក ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៨។

**កម្មវត្ថុ៖** ការពង្រឹងការអនុវត្តគោលនយោបាយវត្តសង្គហកុមារនៅតាមវត្តអារាម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមបង្គំទូលថ្វាយ ប្រគេន ជម្រាបជូនសម្តេច ព្រះរាជាគណៈ ព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការ និងព្រះសង្ឃគ្រប់ព្រះអង្គ លោក លោកស្រី ប្រធានមន្ទីរធម្មការ និងសាសនាគ្រប់រាជធានីខេត្ត ព្រះមេត្តា-មេត្តាពង្រឹងការអនុវត្តប្រកាសលេខ ១៦៣/១៨ ក.ធ.ស.ប្រក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ស្តីពី **"គោលនយោបាយវត្តសង្គហកុមារ"** ដើម្បីបង្កើនកិច្ចការពារកុមារតាមសហគមន៍ និងនៅតាមវត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រធានមន្ទីរធម្មការ និងសាសនា គ្រប់រាជធានីខេត្ត មានភារកិច្ចសហការជាមួយព្រះមេគណ ព្រះចៅអធិការ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថាប័នពាក់ព័ន្ធនានា ដោះស្រាយករណីរំលោភបំពានលើកុមារ និងផ្ញើរបាយការណ៍ប្រចាំខែមកក្រសួង ដើម្បីមានមូលដ្ឋានរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីកិច្ចការពារកុមារក្នុងវិស័យធម្មការ និងសាសនា។ ក្រសួងធម្មការ និងសាសនាមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា សម្តេច ព្រះរាជាគណៈ ព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការ និងព្រះសង្ឃគ្រប់ព្រះអង្គ លោក លោកស្រី ប្រធានមន្ទីរធម្មការ និងសាសនាគ្រប់រាជធានីខេត្ត ពិតជាយកព្រះទ័យ និងយកចិត្តទុកដាក់អនុវត្តនូវសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូម សម្តេច ព្រះរាជាគណៈ ព្រះមេគណ ព្រះអនុគណ សហការីគណ ព្រះចៅអធិការ និងព្រះសង្ឃគ្រប់ព្រះអង្គ លោក លោកស្រី ព្រះមេត្តា-មេត្តាទទួលនូវការគោរពសក្ការៈ និងសេចក្តីរាប់អានដ៏ស្មោះស្មគ្រ័ អំពីខ្ញុំព្រះករុណា ខ្ញុំ។

ថ្ងៃ ចន្ទ ៤កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា**

ឈិត_សុខុន

**ចម្លងជូន៖**
- គណៈសង្ឃនាយកទាំងពីរគណៈ
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីខេត្ត
- មន្ទីរធម្មការ និងសាសនារាជធានីខេត្ត
- ស្ថាប័នពាក់ព័ន្ធ
- អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ១៦៣/១៨ ក.ធ.ស.ប្រក

ថ្ងៃពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

### ប្រកាស
### ស្តីពីការដាក់ឱ្យប្រើប្រាស់
### គោលនយោបាយ "វត្តសង្គហកុមារ"

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/១៩ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- យោងអនុក្រឹត្យលេខ ១៥៤អនក្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងប្រកាសលេខ ៦៤៩/១១ ក.ធ.ស.ប្រក.ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងចំណុះផ្នែកនានាក្រោមឱវាទ អង្គភាពអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និងសាសនា
- យោងតម្រូវការចាំបាច់

### សម្រេច

**ប្រការ១** ដាក់ឱ្យប្រើប្រាស់ គោលនយោបាយ "វត្តសង្គហកុមារ" ដើម្បីបង្កើតបរិយាកាសកិច្ចការពារកុមារតាមសហគមន៍ និងនៅតាមវត្តអារាមក្នុងព្រះរាជាណាក្រកម្ពុជា។

**ប្រការ២** ខុទ្ទកាល័យ អគ្គនាយកដ្ឋានកិច្ចការសាសនា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា គ្រឹះស្ថានពុទ្ធិកសិក្សា គ្រប់វត្តអារាម និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៣** ប្រកាសនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**ហ៊ឹម ឆែម**

**ចម្លងជូន-ជូន**
- សម្តេចព្រះមហាសង្ឃរាជទាំងពីគណ:
- គណ:សង្ឃនាយកទាំងពីគណ:
- ក្រសួងមហាផ្ទៃ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ដើម្បីថ្វាយ-ជូនជ្រាប**
- សាលាពុទ្ធិកសិក្សា
- សាលាគណរាជធានី-ខេត្ត
- សាលារាជធានី-ខេត្ត
- មន្ទីរធម្មការ និងសាសនា
- (ដូចប្រការ២ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# 393, តិវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី**
**សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា**

# និវេទនកថា

ព្រះពុទ្ធសាសនា ជាសាសនាដែលបានលើកកម្ពស់យ៉ាងខ្លាំងក្លាដល់កិច្ចការពារកុមារ ដូចដែលមានបញ្ជាក់ក្នុងសង្គហធម៌របស់មាតាបិតា ចំពោះបុត្រ និងព្រហ្មវិហារធម៌ទាំងបួនជាដើម។ គណៈសង្ឃនាយកនៃគណៈធម្មយុត្តិកនិកាយ បានអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិកុមារ ដោយបានបង្កើតជាកម្មវិធីអប់រំព្រះពុទ្ធសាសនាតាមសហគមន៍ និងតាមវិទ្យុសម្លេងធម្មយុត្ត ដើម្បីលើកកម្ពស់ការយល់ដឹងដល់ព្រះសង្ឃ និងផ្ទេរចំណេះដឹងដល់ពុទ្ធបរិស័ទជាមាតាបិតា អាណាព្យាបាល ក្រុមគ្រួសារ និងសហគមន៍ ដើម្បីផ្លាស់ប្តូរឥរិយាបថមកជាវិជ្ជមានក្នុងការអប់រំដល់កុមារ ប្រកបដោយអហិង្សាធម៌ និងជៀសផុតអំពើហិង្សា។

គណៈសង្ឃនាយកសូមគាំទ្រ និងជឿជាក់ថាគោលនយោបាយវត្តសង្គហកុមារ ដែលបង្កើតឡើងដើម្បីឧត្តមប្រយោជន៍របស់កុមារ ក្នុងការធានានូវសុវត្ថិភាពកុមារតាមវត្តអារាម ដើម្បីឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពានលើកុមារ ទាំងករណីដែលបានរាយការណ៍ ទាំងករណីសង្ស័យអំពីអំពើហិង្សា ឬការរំលោភបំពានលើកុមារ។

គណៈសង្ឃនាយកគណៈធម្មយុត្តិកនិកាយសូមឱ្យព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការ និងព្រះសង្ឃគ្រប់វត្តចូលរួមអនុវត្តគោលនយោបាយវត្តសង្គហកុមារ អោយមានប្រសិទ្ធភាព និងជាប្រចាំដើម្បីរួមចំណែកទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារនៅកម្ពុជា។

ថ្ងៃសុក្រ ៧កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨

**គណៈសង្ឃនាយក**

បួរ_គ្រី

ទន្លេបទុមធម្មយុត្ត សង្កាត់ចតុមុខ ខណ្ឌដូនពេញ ភ្នំពេញ - ព្រះរាជាណាចក្រកម្ពុជា Tél. : + (855) 23 633 22 45 / E-mail : botumdhamma@yahoo.com

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈសង្ឃនាយក**
**នៃព្រះរាជាណាចក្រកម្ពុជា**
លេខៈ ០៨៧/១៨ ស.ន.ក.ជ

# និវេទនកថា

ព្រះពុទ្ធបានសម្តែងថាកុមារស្ថិតក្នុងប្រភេទជាវ័យផុយស្រួយ តែក៏ជាទំពាំងស្នងឫស្សី មិនអាចខ្វះបានសម្រាប់គ្រួសារ ព្រះពុទ្ធសាសនា និងសង្គមជាតិ។ កុមារដែលរីកធំជាត់ឡើងប្រកបដោយសក្តានុពល ទាមទារឱ្យមានសុខុមាលភាពល្អបួនប្រការ គឺសុខភាពផ្លូវកាយ សុខភាពខួរក្បាល សុខភាពស្មារតី និងសុខភាពផ្លូវចិត្ត។ ដើម្បីសម្រេចតាមវត្ថុបំណងទាំងនេះ កុមារត្រូវតែទទួលបានកិច្ចការពារជៀសផុតពីអំពើហិង្សាគ្រប់ទម្រង់។ កន្លងមកគណៈសង្ឃនាយកនៃគណៈមហានិកាយ បានអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងចូលរួមក្នុងការកសាងសង្គមមួយប្រកបដោយអហិង្សា។

គណៈសង្ឃនាយកសូមគាំទ្រ និងជឿជាក់ថាគោលនយោបាយវត្តសង្គហកុមារ ដែលបង្កើតឡើងដើម្បីឧត្តមប្រយោជន៍របស់កុមារ ក្នុងការធានានូវសុវត្ថិភាពកុមារតាមវត្តអារាម ដើម្បីឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពានលើកុមារ ទាំងករណីដែលបានរាយការណ៍ ទាំងករណីសង្ស័យអំពីអំពើហិង្សា ឬការរំលោភបំពានលើកុមារ។

គណៈសង្ឃនាយកសូមឱ្យព្រះមេគណ ព្រះអនុគណ ព្រះចៅអធិការ និងព្រះសង្ឃគ្រប់វត្តចូលរួមអនុវត្តគោលនយោបាយវត្តសង្គហកុមារ អោយមានប្រសិទ្ធភាព និងជាប្រចាំក្នុងការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារនៅកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍន៍ជាតិជាមួយរាជរដ្ឋាភិបាល។៚

ថ្ងៃ សុក្រ ៣ កើត ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៨

**គណៈសង្ឃនាយក**

**នន្ទ ង៉ែត**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៣៧៨/១៨ ក.ធ.ស.សសរ

ថ្ងៃ [illegible] ខែបឋមសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រង និងគ្រូឧទ្ទេសនាម វត្តសង្គហៈកុមារ នៅកម្ពុជា

**យោង:**
- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស០១៩៦ រកម//១៩ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- អនុក្រឹត្យលេខ ១៥៤ អន ក្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- ប្រកាសលេខ៦៤៩/១១ ក ធ ស ប្រក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់ការិយាល័យថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងចំណុះផ្នែកនានាក្រោមឱវាទ អង្គភាពអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និងសាសនា
- ប្រកាសលេខ០៨៧/១៥ ក ធ ស ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណកម្មការ រៀបចំមេរៀនការទប់ស្កាត់អំពើហិង្សាលើកុមារ ក្នុងកម្មវិធីសិក្សាទាំងបីកម្រិត។
- តម្រូវការចាំបាច់

## សម្រេច

**ប្រការ១៖** ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងវត្តសង្គហៈកុមារ និងគ្រូឧទ្ទេសនាម ដើម្បីអនុវត្តកម្មវិធីកិច្ចការពារកុមារដោយសុវត្ថិភាពតាមវត្តអារាម ដែលមានសមាសភាពដូចខាងក្រោម៖

**ក-គណៈកម្មការកណ្តាល**:

| | | | |
|---|---|---|---|
| ១- | សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី | **នន់ ង៉ែត** | ព្រះសហប្រធានកិត្តិយស |
| ២- | សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី | **បួរ គ្រី** | ព្រះសហប្រធានកិត្តិយស |
| ៣- | សម្តេចព្រះមហាសុមេធាធិបតី | **នន្ទ ង៉ែត** | សមាជិកអចិន្ត្រៃយ៍កិត្តិយស |
| ៤- | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | | ប្រធាន |
| ៥- | សម្តេចព្រះពោធិវង្ស | **អ៊ំ លឹមហេង** | អនុប្រធាន |
| ៦- | សម្តេចព្រះមង្គលទេព្វាចារ្យ | **ង៉ុយ អានេតា** | អនុប្រធាន |
| ៧- | សម្តេចព្រះឧត្តមចរិយាបណ្ឌិត | **ឈឹង ប៊ុនឈា** | អនុប្រធានអចិន្ត្រៃយ៍ |


# 393, តិរវិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

| | | | |
|---|---|---|---|
| ៨- | សម្តេចព្រះពុទ្ធជ័យមុនី | **ឃឹម សន** | សមាជិក |
| ៩- | ព្រះពុទ្ធឃោសាចារ្យបណ្ឌិត | **ឃី សុវណ្ណរតនា** | សមាជិក |
| ១០- | ព្រះឧបលីវង្ស | **ជួន សារឿន** | សមាជិក |
| ១១- | ព្រះសុមេធវង្សបណ្ឌិត | **សុខ ប៊ុនធឿន** | សមាជិក |
| ១២- | ព្រះវិន័យសំវរៈ | **ស៊ឹម សារ៉ាន** | សមាជិក |
| ១៣- | ព្រះមេត្តមុនី | **រឿង ទិបុល** | សមាជិក |
| ១៤- | ឯកឧត្តមបណ្ឌិត | **សេង សុមុនី** | សមាជិកអចិន្ត្រៃយ៍ |
| ១៥- | ឯកឧត្តម | **ជា ណារ៉េត** | សមាជិក |
| ១៦- | លោក | **ឆន់ ផាន់លី** | សមាជិក |
| ១៧- | លោក | **ឈឹម សីហា** | សមាជិក |
| ១៨- | តំណាងអង្គការយូនីសេហ្វ (UNICEF) | | សមាជិក |

គណៈគ្រប់គ្រងនេះមានតួនាទីភារកិច្ចគ្រប់គ្រង ដឹកនាំ កោះប្រជុំ ណែនាំ ដំណើការអនុវត្តកម្មវិធីកិច្ចការពារកុមារតាមវត្តអារាម ដោះស្រាយតម្រូវការនានារបស់គណកម្មការនីមួយៗពិនិត្យ និងសម្រេចគ្រប់សកម្មភាព ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

## ខ-លេខាធិការដ្ឋាន:

ក្រុមលេខាធិការដ្ឋានវត្តសង្គហកុមារ មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | សម្តេចព្រះពុទ្ធជ័យមុនី | **ឃឹម សន** | ប្រធាន |
| ២- | ឯកឧត្តមបណ្ឌិត | **សេង សុមុនី** | អនុប្រធាន |
| ៣- | ព្រះមហា | **ស៊ូ ពិសិដ្ឋ** | សមាជិក |
| ៤- | ព្រះមហា | **ទ៉ុន ចាន់ថារី** | សមាជិក |
| ៥- | លោក | **ស្រី សុវណ្ណមុនី** | សមាជិក |
| ៦- | លោកស្រី | **ហោ ផល្លីន** | សមាជិក |
| ៧- | លោក | **កែវ សុភិវឌ្ឍន៍** | សមាជិក |
| ៨- | លោក | **ឡូន ស្តេចតក្តី** | សមាជិក |
| ៩- | លោក | **ចាន់ ធឿនវណ្ណារ៉ា** | សមាជិក |
| ១០- | លោក | **ប៉ែន សុធា** | សមាជិក |

លេខាធិការដ្ឋានវត្តសង្គហកុមារ មានតួនាទីភារកិច្ចទទួលខុសត្រូវលើការងាររដ្ឋបាល គ្រប់គ្រងឯកសារនានា ធ្វើលិខិតកោះប្រជុំ ប្រមូលផ្តុំព័ត៌មាន រៀបចំប្រតិទិនការងារ ស្រង់ស្ថិតិ តាមដានសកម្មភាព ពិនិត្យវាយតម្លៃ ធ្វើរបាយការណ៍ ស្នើសុំយោបល់សម្រេច និងធ្វើសកម្មភាពនានាតាមការប្រគល់ឲ្យរបស់គណកម្មការកណ្តាល។

## គ-គ្រូឧទ្ទេសនាមថ្នាក់ជាតិ:

ត្រូវបានទទួលស្គាល់គ្រូឧទ្ទេសនាមវត្តសង្គហកុមារថ្នាក់ជាតិ ដើម្បីអនុវត្តកម្មវិធីកិច្ចការពារកុមារដោយសុវត្ថិភាពតាមវត្តអារាម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ព្រះសុមេធវង្សបណ្ឌិត | **សុខ ប៊ុនធឿន** |
| ២- | ព្រះឧត្តមប្រិយ៍ជា | **អន ឆានអាន** |
| ៣- | ឯកឧត្តមបណ្ឌិត | **សេង សុមុនី** |
| ៤- | លោកស្រី | **ចាន់ ភព្ញា** |
| ៥- | ព្រះមហា | **នី សុខបញ្ញា** |
| ៦- | លោក | **ឡូច ម៉ៃ** |
| ៧- | លោក | **ឆេង ឆវណ្ណនី** |

គ្រូឧទ្ទេសនាមវត្តសង្គហកុមារថ្នាក់ជាតិ មានតួនាទីភារកិច្ចទទួលខុសត្រូវលើការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ក្រោមជាតិ និងជនបង្គោលតាមវត្តអារាមនៅទូទាំងប្រទេស។

**ប្រការ២៖** គណៈកម្មការនីមួយៗ ត្រូវចូលរួមប្រជុំ និងរាយការណ៍ទៀងទាត់មួយខែម្តង និងប្រជុំចាំបាច់តាមការយាង និមន្ត និង អញ្ជើញរបស់ប្រធាន។

**ប្រការ៣៖** ខុទ្ទការល័យ អគ្គនាយកដ្ឋានកិច្ចការសាសនា អគ្គាធិការដ្ឋានពុទ្ធិកសិក្សា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ គ្រប់សាលាពុទ្ធិកសិក្សា គ្រប់វត្តអារាម និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**ហ៊ឹម ឆែម**

**ចម្លងជូន-ជូន**

- សម្តេចព្រះមហាសង្ឃរាជទាំងពីគណៈ
- គណៈសង្ឃនាយកទាំងពីគណៈ
- ក្រសួងមហាផ្ទៃ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ដើម្បីថ្វាយ-ជូនជ្រាប**

- សាលាពុទ្ធិកសិក្សា
- សាលាគណរាជធានី-ខេត្ត
- សាលារាជធានី-ខេត្ត
- មន្ទីរធម្មការ និងសាសនា
- (ដូចប្រការ៣ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# ជំពូកទី១
# គោលនយោបាយវត្តសង្គហកុមារ

## ១. សេចក្តីផ្តើម និងគោលបំណង

ជាកិច្ចឆ្លើយតប ចំពោះការសិក្សាស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាឆ្នាំ២០១៣ ក្រសួងធម្មការនិងសាសនា និងសម្តេចសង្ឃនាយកទាំងពីរគណៈ ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការយូនីសេហ្វ (UNICEF) ប្តេជ្ញាចិត្តលើកកម្ពស់តួនាទីវត្តអារាម និងព្រះសង្ឃក្នុងការបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនិងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ប្រកបដោយប្រសិទ្ធភាព និងដើម្បីធ្វើឱ្យវត្តអារាមកាន់តែមានសុវត្ថិភាពសម្រាប់កុមារទាំងនៅក្នុងបរិវេណវត្តនិងក្នុងសហគមន៍។ សកម្មភាពទាំងអស់នេះរួមមាន៖

១) ការកសាងសមត្ថភាពព្រះសង្ឃ ដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារតាមរយៈអធិការកិច្ចទូទៅនៃពុទ្ធិកសិក្សា ដែលបានទទួលការជ្រោមជ្រែងក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីដាក់បញ្ចូលទៅក្នុងការបណ្តុះបណ្តាលទាំងបីកម្រិត (បឋម មធ្យម និងឧត្តម)

២) ការចូលរួមយ៉ាងសកម្មរបស់ព្រះសង្ឃក្នុងការអប់រំសហគមន៍ និងលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ ដើម្បីបង្ការនិងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងដើម្បីបង្ការការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ អំពើហិង្សានិងការរំលោភបំពានលើកុមារនិងការឆ្លើយតប។

៣) ការបង្កើតកម្មវិធីការពារកុមារតាមវត្តអារាម រួមទាំងយន្តការការពារសុវត្ថិភាពសព្វជ្រុងជ្រោយ ដើម្បីឆ្លើយតបចំពោះករណីសង្ស័យ និងករណីដែលបានរាយការណ៍អំពីការរំលោភបំពានលើកុមារណាម្នាក់នៅក្នុងបរិវេណវត្ត និងការផ្តួចផ្តើមឱ្យមានផែនការពិនិត្យតាមដាន និងរាយការណ៍ គោលនយោបាយវត្តសង្គហកុមារនេះ(ឬហៅថាគោលនយោបាយសុវត្ថិភាពកុមារតាមវត្តអារាម) គឺជាផ្នែកមួយនៃយន្តការសព្វជ្រុងជ្រោយនៅតាមវត្តអារាម ដើម្បីឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពានលើកុមារ ទាំងករណីដែលបានរាយការណ៍ ទាំងករណីសង្ស័យអំពីអំពើហិង្សា ឬការរំលោភបំពានលើកុមារ។

### គោលនយោបាយនេះ រួមមាន

**ក**)ចាត់តាំងជនបង្គោលការពារសុវត្ថិភាពកុមារ ដែលមានការទទួលខុសត្រូវក្នុងការរាយការណ៍ និងពិនិត្យតាមដានក្នុងវត្តនីមួយៗ និងនៅក្នុងកម្រិតផ្សេងៗនៃរចនាសម្ព័ន្ធព្រះពុទ្ធសាសនាកម្ពុជា។

ខ)យន្តការលម្អិតសម្រាប់ការរាយការណ៍ និងការឆ្លើយតបចំពោះករណីដែលបានរាយការណ៍ និងក្រមសីលធម៌សម្រាប់ព្រះសង្ឃ និងមនុស្សពេញវ័យដទៃទៀតដែលជាប់ពាក់ព័ន្ធជាមួយវត្ត។ ដើម្បីធានានូវប្រសិទ្ធភាព គោលនយោបាយនេះ ក៏មានភ្ជាប់ជាមួយ កម្មវិធីវត្តសង្គហកុមារ (ឬអាចហៅថាកម្មវិធីកិច្ចការពារកុមារតាមវត្តអារាម) ដែលកម្មវិធីដើម្បីធានាបាននូវប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយវត្តសង្គហកុមារ និងបង្កើតនូវបរិយាកាសកិច្ចការពារកុមារទាំងក្នុងសហគមន៍ និងតាមវត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះ និងនិយមន័យ

ក្រសួងធម្មការនិងសាសនា និងសម្ដេចសង្ឃនាយកទាំងពីរគណៈពោលគឺគណៈមហានិកាយ និងគណៈធម្មយុត្ត យល់ច្បាស់ថា “ការរំលោភបំពាន”ឬ “ការធ្វើបាប” គឺរួមបញ្ចូលគ្រប់ទម្រង់ទាំងអស់នៃការធ្វើបាបផ្នែកផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការព្រងើយកន្តើយ ឬការប្រព្រឹត្តដោយប្រងើយកន្តើយ ឬការជួញដូរ និងការកេងប្រវ័ញ្ចន៍ដទៃទៀតដែលផ្ដល់លទ្ធផលឱ្យមានគ្រោះថ្នាក់ជាក់ស្ដែង ឬជាសក្ដានុពលចំពោះសុខភាព ការរស់រាន ការអភិវឌ្ឍ ឬសេចក្ដីថ្លៃថ្នូររបស់កុមារ[1]។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ គឺផ្អែកលើច្បាប់កម្ពុជា អនុសញ្ញាស្ដីពីសិទ្ធិកុមារ អង្គការសុខភាពពិភពលោក និងអង្គការអន្តរជាតិខាងពលកម្ម។

**កុមារ ៖** កុមារគឺជាជនទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ដែលប្រទេសកម្ពុជាផ្ដល់សច្ចាប័នក្នុងឆ្នាំ ១៩៩២។

**មនុស្សពេញវ័យ ៖** មនុស្សពេញវ័យ គឺជាជនទាំងឡាយណាដែលមានអាយុ១៨ ឆ្នាំឡើងទៅ។

**ការរំលោភបំពានផ្នែករាងកាយ ៖** ជាការបំពានដែលធ្វើឱ្យមានគ្រោះថ្នាក់ផ្នែករាងកាយជាក់ស្ដែង ឬគ្រោះថ្នាក់ផ្នែករាងកាយដែលកើតចេញពីអន្តរទំនាក់ទំនង ឬកង្វះអន្តរទំនាក់ទំនងឬការគំរាមដោយយកលេសណាមួយពីសំណាក់ឪពុកម្ដាយ ឬអ្នកស្ថិតក្នុងអំណាចមេបា មុខតំណែងទទួលខុសត្រូវ ឬអ្នកដែលទទួលបានការទុកចិត្ត។ ហេតុការណ៍ទាំងនោះ អាចជាសកម្មភាពដែលកើតឡើងតែមួយលើក ឬកើតឡើងច្រើនលើក។ ឧទាហរណ៍ សកម្មភាពរំលោភបំពានកុមារ អាចមានដូចជា៖ ការទះកំផ្លៀង ការវាយដោយដៃ ឬវត្ថុ ការដាល់ ការធាក់ ការច្រាន ការវាយ ការក្ដិច និងការគំរាមថានឹងបង្កគ្រោះថ្នាក់[2]។

---

[1] និយមន័យរបស់អង្គការសុខភាពពិភពលោកអំពីការរំលោភបំពានកុមារ ដូចមានចែងនៅក្នុងរបាយការណ៍ពិគ្រោះយោបល់ស្ដីពីការបង្ការការរំលោភបំពានលើកុមារ ដោយអង្គការ WHO ឆ្នាំ ១៩៩៩

[2] ដដែល

**ការរំលោភបំពានផ្លូវភេទ ៖** ការបង្ខិតបង្ខំ ឬលួងលោមកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ ដែលកុមារមិនទាន់យល់ច្បាស់ពេញលេញ  ពុំអាចផ្តល់ការយល់ព្រមដោយផ្អែកលើព័ត៌មានដែលបាន ផ្តល់ឬដែលកុមារមិនទាន់មានលក្ខណៈអភិវឌ្ឍគ្រប់គ្រាន់អាចទទួលយកបាន  និងពុំអាចផ្តល់ការយល់ព្រម ឬដែលបំពានច្បាប់ ឬជាការហាមឃាត់របស់សង្គម[3]។ ការរំលោភបំពាននេះ រួមបញ្ចូលទាំងភាសាកាយវិការ ការនិយាយបញ្ឆិតបញ្ឆៀង មតិយោបល់ ឬប្រយោគមិនសមស្របដែលមានលក្ខណៈផ្លូវភេទ ឬមានលក្ខណៈផ្ទាល់ខ្លួនចំពោះកុមារ។

**ការរំលោភបំពានផ្នែកផ្លូវចិត្ត ៖** ការរំលោភបំពានផ្លូវចិត្តកើតមានឡើង  នៅពេលកុមារត្រូវបានប្រានចោលច្រំដែលៗ  បដិសេធមិនផ្តល់ឱ្យនូវក្តីស្រឡាញ់  ផ្តាច់ទំនាក់ទំនងមនោសញ្ចេតនាក្នុងកម្រិតសមស្របជាមួយអ្នកថែទាំចម្បង ឬរងការភ័យខ្លាចដោយការគំរាម។ ការរំលោភបំពាននេះ អាចរួមមានដូចជា ការជេរ ការធ្វើឱ្យអាម៉ាស់ ការបង្អាប់ ការគំរាម ការបន្លាច ការរើសអើង ការចម្អក ឬមិនផ្តល់ភាពកក់ក្តៅជាបន្តបន្ទាប់ពីឪពុកម្តាយ ឬអ្នកមើលថែរហូតដល់អាចប៉ះពាល់ដល់ការលូតលាស់ផ្នែករាងកាយនិងផ្លូវចិត្តរបស់កុមារ។

**ការព្រងើយកន្តើយចំពោះកុមារ ៖** ការព្រងើយកន្តើយ  គឺជាការខកខានអូសបន្លាយ  ឬការបដិសេធជាចេតនា មិនផ្តល់ឱ្យកុមារនូវ  ទឹកស្អាត  អាហារ  ជម្រក  ការគាំទ្រផ្នែកផ្លូវចិត្ត ឬក្តីស្រឡាញ់  អនាម័យ  ឬការមើលខុសត្រូវឬការថែទាំរហូតដល់ធ្វើឱ្យសុខភាព  និងការអភិវឌ្ឍរបស់កុមារត្រូវប្រឈមហានិភ័យ។ សកម្មភាពទាំងអស់នេះរួមមានដូចជា ការខកខានមិនបានមើលខុសត្រូវ និង  ការពារកុមារឱ្យបានសមស្របពីគ្រោះថ្នាក់នានាឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។

**ការកេងប្រវ័ញ្ចន៍លើកុមារ ៖** ការជួញដូរ  ឬការកេងប្រវ័ញ្ចន៍ដទៃទៀតលើកុមារ  សំដៅលើការប្រើប្រាស់កុមារនៅក្នុងការងារ  ឬសកម្មភាពដទៃទៀត  ដើម្បីផ្តល់ប្រយោជន៍ឱ្យអ្នកផ្សេង។ សកម្មភាពនេះ  រួមមានជាអាទិ៍ដូចជា  ពលកម្មកុមារ  រូបភាព  និងសម្ភារៈអាសអាភាសរបស់កុមារ  និងពេស្យាចារកុមារ។  សកម្មទាំងអស់នេះ  បំផ្លិចបំផ្លាញសុខភាពផ្លូវកាយ  ផ្លូវចិត្តរបស់កុមារ  ការអប់រំ  ឬការអភិវឌ្ឍផ្នែកស្មារតី សីលធម៌ ឬចិត្តសង្គមរបស់កុមារ[4]។

**ការកេងប្រវ័ញ្ចន៍ផ្លូវភេទកុមារ ៖** ការប្រើប្រាស់ភាពងាយរងគ្រោះរបស់កុមារ  អំណាច  ឬការទុកចិត្តពីកុមារ  ដើម្បីគោលបំណងផ្លូវភេទ  ដោយរួមមាន  ការទទួលអត្ថប្រយោជន៍ជាប្រាក់ជាផ្នែកខាងសង្គម ឬនយោបាយពីការកេងប្រវ័ញ្ចន៍លើជនដទៃ។ សកម្មភាពនេះរួមមានដូចជាពេស្យាចារកុមារការជួញដូរកុមារ និងរូបភាព និងសម្ភារៈអាសអាភាសកុមារ។

---

[3] ដដែល

[4] ដដែល

**ការល្បួងលួងលោមតាមអ៊ីនធឺណិត ៖** ជាដំណើរការ នៃការបង្កើតឱ្យមានការប្រាស្រ័យទាក់ទងគ្នា ជាមួយកុមារតាមអ៊ីនធឺណែត ដោយមានគោលបំណង ដើម្បីទាក់ទាញចិត្ត សម្របសម្រួល ឬជម្រុញលើកទឹកចិត្តកុមារឱ្យពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ។ សកម្មភាពផ្លូវភេទទាំងនោះ រួមមានទាំងសកម្មភាពមុនការជួបជាក់ស្តែងជាមួយជនល្មើស ដូចជាការរំលោភបំពានផ្លូវភេទកុមារ តាមវែបខេម (Webcam) ឬការផលិតរូបភាព និងសម្ភារៈអាសអាភាស នៃកុមារនិងសម្ភារៈអាសអាភាសដែលកុមារផលិតដោយខ្លួនឯង។

**ពលកម្មកុមារ ៖** ការធ្វើឱ្យកុមារចូលរួមក្នុងការងារ ដែលអាចមានគ្រោះថ្នាក់ ឬអាចរំខានដល់ការអប់រំរបស់កុមារឬបង្កគ្រោះថ្នាក់ចំពោះសុខភាព ឬការអភិវឌ្ឍផ្នែករាងកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ ឬផ្នែកសង្គមរបស់កុមារ[5]។ បន្ថែមលើនេះទៀត បទដ្ឋានអន្តរជាតិហាមឃាត់ការឱ្យកុមារចូលរួមក្នុងសកម្ម ភាពផ្នែកសេដ្ឋកិច្ចណាមួយនៅពេលកុមារអាយុក្រោម១២ឆ្នាំ ហើយកុមារអាយុចន្លោះ១២ដល់១៤ឆ្នាំអាច ចូលរួមធ្វើការងារស្រាលៗ ដែលមិនទំនងជាបង្កគ្រោះថ្នាក់ដល់សុខភាពឬការអភិវឌ្ឍរបស់ពួកគេ[6]។

**ការរុកកួនឆាឆៅ ៖** ការរុកកួនឆាឆៅ គឺជាពាក្យដែលត្រូវបានប្រើប្រាស់សម្រាប់ការប្រព្រឹត្តមិនល្អក្នុងទម្រង់ជាច្រើន ដោយភាគច្រើនកើតមាននៅតាមសាលារៀននិងកន្លែងធ្វើការ។ សកម្មភាពនេះត្រូវបានកំណត់លក្ខណៈ ដោយជនម្នាក់ទទួលរងបទពិសោធន៍ច្រំដែលៗ នូវការឈ្លានពានផ្នែករាងកាយនិង/ឬផ្លូវចិត្ត រួមទាំងការចម្អន់ ការជេរ ការសើចចម្អក ការគំរាម ការបៀតបៀន ឡកឡឺយ សម្លុត ការផាត់ចេញផ្នែកសង្គម ឬពាក្យចចាមអារ៉ាម[7]។ ក្នុងបរិបទនៃគោលនយោបាយនេះ ការធ្វើបាបតាមធម្មតាច្រើនប្រព្រឹត្តដោយកុមារម្នាក់ចំពោះកុមារម្នាក់ទៀត។

## ៣. វិសាលភាព

គោលនយោបាយនេះ ត្រូវអនុវត្តចំពោះមនុស្សទាំងអស់ដែលពាក់ព័ន្ធជាមួយវត្តអារាម រួមទាំងគណៈគ្រប់គ្រងវត្ត ព្រះសង្ឃ និងអ្នកដែលមានទំនាក់ទំនងជាមួយវត្តអារាមទាំងអស់ដូចជា អាចារ្យ គណៈកម្មការវត្ត តាជី ដូនជី ក្មេងវត្ត និងអ្នកដែលរស់នៅក្នុងវត្ត និង/ឬ អ្នកស្ម័គ្រចិត្តមប្រើការក្នុងវត្ត។

[5] មាត្រា ៣២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, អនុសញ្ញាលេខ ១៨២ របស់អង្គការ ILO ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

[6] អនុសញ្ញាលេខ ១៣៨ របស់អង្គការ ILO ស្តីពីប្រាក់ឈ្នួលអប្បបរមា

[7] អង្គការសុខភាពពិភពលោក http://www.who.int/bulletin/volumes/88/6/10-077123/en/

## ៤. គោលការណ៍មគ្គុទ្ទេសក៍

**ក. គោលនយោបាយនេះ** ត្រូវបានចង្អុលបង្ហាញដោយគោលការណ៍មគ្គុទ្ទេសក៍ចំនួនបួនរបស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារៈ

- ការមិនរើសអើង (ផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ សាសនា ភាសា វប្បធម៌ យេនឌ័រ ឬសមត្ថភាព)
- ត្រូវផ្តល់អត្ថិភាពចំពោះឧត្តមប្រយោជន៍របស់កុមារ
- សិទ្ធិមានជីវិត សិទ្ធិរស់រាន និងសិទ្ធិក្នុងការអភិវឌ្ឍ
- ការគោរពចំពោះទស្សនៈយល់ឃើញរបស់កុមារ។

**បន្ថែមលើគោលការណ៍ទាំងអស់នេះ មានគោលការណ៍មួយចំនួនទៀតដែលត្រូវអនុវត្តផងដែរមានៈ**

- **សិទ្ធិមានជីវិតក្នុងគ្រួសារ ឬទទួលការថែទាំនៅក្នុងសហគមន៍ៈ** កុមារទាំងអស់មានសិទ្ធិរស់នៅជាមួយមនុស្សដែលស្រឡាញ់ និងថែទាំពួកគេដោយល្អ គឺគ្រួសាររបស់ខ្លួនឬដោយអ្នកមើលថែក្នុងករណីគ្រួសារពុំអាចមើលថែពួកគេបាន។
- **ការមិនអត់ឱនកម្រិតសូន្យចំពោះអំពើហិង្សាៈ**ការរំលោភបំពានឬការកេងប្រវ័ញ្ចន៍។ជានិច្ចកាលគឺមិនអាចមានលេសណាមួយដើម្បីអត់ឱនចំពោះអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចន៍លើកុមារក្នុងបរិបទវត្តអារាម និងសហគមន៍នោះឡើយ មិនថានោះជាការអនុវត្តតាមបែបប្រពៃណី បទដ្ឋាននិងអាកប្បកិរិយាសង្គមដែលត្រូវបានទទួលយកក៏ដោយ។
- **ការរក្សាការសម្ងាត់ៈ** បានន័យថា រាល់ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបានអំពីកុមារណាម្នាក់/កុមារច្រើននាក់ និងមនុស្សពេញវ័យណាម្នាក់ ឬមនុស្សពេញវ័យច្រើននាក់នឹងត្រូវបានការពារនៅពេលមានការរាយការណ៍ការស៊ើបអង្កេត ឬតាមដានបន្តលើកង្វល់ទាក់ទងជាមួយកិច្ចការពារកុមារ។ ព័ត៌មានទាក់ទងជាមួយករណីអាចចែករំលែកបានតែជាមួយអ្នកទាំងឡាយណាដែលចាំបាច់ត្រូវដឹងប៉ុណ្ណោះ។

**ខ. គោលនយោបាយនេះ** ប្រកាន់ខ្ជាប់តាមគោលការណ៍ពុទ្ធសាសនាដូចមានចែងក្នុងព្រះត្រៃបិដកថាកុមារគ្រប់រូប(រួមទាំងកុមារដែលកំពុងស្ថិតក្នុងភេទជាសាមណេរ)មានសិទ្ធិទទួលបានកុមារភាពដែលរួចផុតពីអំពើហិង្សា ការរំលោភបំពាន ការបំភ្លេច និងការកេងប្រវ័ញ្ចន៍ ហើយការបដិសេធសិទ្ធិទាំងអស់នេះ គឺមិនត្រូវបានទទួលយក ឬមានហេតុផលអាចទទួលយកបានឡើយ ម្យ៉ាងវិញទៀត វត្តទាំងអស់ត្រូវមានការទទួលខុសត្រូវផ្អែកសីលធម៌ ក៏ដូចជាផ្អែកច្បាប់ក្នុងការធានាយ៉ាងណាឱ្យព្រះសង្ឃ និងកម្មវិធីដែលខ្លួនគាំទ្រ មិនត្រូវដាក់ឱ្យកុមារប្រឈមហានិភ័យចំពោះគ្រោះថ្នាក់ឡើយ។

**គ. គោលនយោបាយនេះ** ក៏ទទួលស្គាល់នឹងតម្រូវឱ្យវត្តទាំងអស់អនុវត្តតាមច្បាប់កម្ពុជាទាក់ទងជាមួយអំពើហិង្សាលើកុមារ និងអនុលោមគោលនយោបាយជាតិស្តីពី ការថែទាំជំនួសសម្រាប់កុមារ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសសម្រាប់កុមារចេញដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា។

## ៥. ការអនុវត្តគោលនយោបាយវត្តសុខុមាលភាពកុមារ

- ព្រះសង្ឃគ្រប់អង្គនិងអ្នកដទៃទៀតដែលមានទំនាក់ទំនងជាមួយវត្តអារាមដូចជា អាចារ្យ គណៈកម្មការ តាជី ដូនជី ក្មេងវត្តនិងមនុស្សពេញវ័យដទៃទៀតដែលស្នាក់នៅក្នុងវត្ត ឬមានទំនាក់ទំនងជាមួយវត្ត ដូចជាអ្នកស្ម័គ្រចិត្តមប្រើការងារក្នុងវត្តជាដើម ចាំបាច់ត្រូវតែដឹងអំពីគោលនយោបាយការពារសុវត្ថិភាពកុមារហើយត្រូវទទួលស្គាល់ជាលាយលក្ខណ៍អក្សរថា ខ្លួនបានទទួល និងបានយល់ច្បាស់អំពីគោលនយោបាយនេះ។ បន្ថែមលើនេះ ត្រូវរៀបចំការពន្យល់ណែនាំពិសេសឱ្យសមស្របតាមក្រុមអាយុ សម្រាប់កុមារកំពុងរស់នៅក្នុងវត្ត (ឧ. សាមណេរ ក្មេងវត្ត និងកុមារដទៃទៀតដែលស្នាក់នៅក្នុងវត្ត) ហើយការបណ្តុះបណ្តាលតាមដានបន្តត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។
- ឯកសារថតចម្លងមួយច្បាប់នៃគោលនយោបាយរក្សាសុវត្ថិភាពកុមារតាមវត្តអារាម នឹងត្រូវយកទៅដាក់នៅទីតាំងដែលគេអាចមើលឃើញបានក្នុងបរិវេណវត្ត។
- សហគមន៍ ជាពិសេស គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ (គ.ក.ន.ក.) និងអ្នកផ្តល់សេវាសង្គមកិច្ចត្រូវដឹងអំពីគោលនយោបាយរក្សាសុវត្ថិភាពកុមារ និងក្រមសីលធម៌នេះផងដែរ។ ការងារនេះ អាចធ្វើឡើងតាមរយៈកម្មវិធីពិសេស ឬនៅក្នុងបរិបទនៃធម្មទេសនាជាប្រចាំ ឬពិធីបុណ្យសាសនាធំៗ។ សមាជិកសហគមន៍ គួរត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ជាបន្ទាន់ នូវរាល់កង្វល់ទាំងឡាយណាអំពីអាកប្បកិរិយា ឬសកម្មភាពរបស់បុគ្គលក្នុងសាសនា ឬបុគ្គលិក ឬអ្នកស្ម័គ្រចិត្តរបស់វត្តចំពោះកុមារណាម្នាក់ (នៅក្នុងឬក្រៅវត្ត)។
- វត្តដែលផ្តល់ជាមណ្ឌលថែទាំដល់កុមារ តម្រូវឱ្យអនុវត្តទៅតាមគោលនយោបាយជាតិស្តីពី:ការថែទាំជំនួសសម្រាប់កុមារ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស សម្រាប់កុមារចេញដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា។

## ការអនុវត្តក្រមសីលធម៌

មនុស្សពេញវ័យទាំងអស់ដែលរស់នៅក្នុងវត្ត ឬមានទំនាក់ទំនងជាមួយវត្ត មានភារកិច្ចត្រូវចុះហត្ថលេខា និងអនុវត្តតាមក្រមសីលធម៌ (ឧបសម្ព័ន្ធក១) ដែលតម្រូវឱ្យពួកគេប្តេជ្ញាចិត្តគោរពតាមគោលការណ៍ដែលមានចែងនៅក្នុងគោលនយោបាយការពារសុវត្ថិភាពកុមារ។ ការប្តេជ្ញាចិត្តនេះ រួមមាន ការប្តេជ្ញាចិត្ត

ដើម្បីលើកកម្ពស់អាកប្បកិរិយាផ្ទាល់ខ្លួន និងអាកប្បកិរិយាវិជ្ជាជីវៈខ្ពស់បំផុតចំពោះសេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ របស់កុមារគ្រប់រូបទាំងអស់ហើយមានភារកិច្ចត្រូវរាយការណ៍អំពីគ្រប់ករណីសង្ស័យអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចន៍លើកុមារ។

ការណែនាំសមស្របតាមអាយុនិងលើកកម្ពស់ការយល់ដឹងស្តីពីក្រមសីលធម៌គួរត្រូវបានធ្វើឡើងសម្រាប់គ្រប់សាមណេរថ្មីៗទាំងអស់ និងសម្រាប់នាពេលបច្ចុប្បន្ន ព្រមទាំងកុមារកំពុងរស់នៅក្នុងវត្ត ហើយឯកសារក្រមសីលធម៌ ដែលមានលក្ខណៈសមស្របសម្រាប់កុមារ គួរត្រូវបានដាក់បង្ហាញនៅកន្លែងរួមណាមួយក្នុងវត្តនិងនៅក្នុងបរិវេណដែលរស់នៅ។

**បន្ថែមលើនេះទៀតចាំបាច់ត្រូវគោរពតាមសេចក្តីណែនាំដូចខាងក្រោម៖**

១. វត្តត្រូវចាត់វិធានការកាត់បន្ថយហានិភ័យនៃការរំលោភបំពានឬការបំពានណាមួយដទៃទៀតចំពោះកុមារនៅក្នុងវត្តតាមរយៈ ការរឹតត្បិតឱកាសដែលមនុស្សធំនៅតែពីរនាក់ជាមួយកុមារ។ នៅពេលដែលដឹងពីស្ថានភាពថា អាចបង្កហានិភ័យដល់កុមារ និងត្រូវដឹងអំពីរបៀបឆ្លើយតបចំពោះស្ថានភាពទាំងអស់នេះប្រកបដោយប្រសិទ្ធភាព។

២. ឯកជនភាពនិងការសម្ងាត់របស់កុមារ រួមទាំងព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានដែលអាចឱ្យកំណត់អត្តសញ្ញាណបាន ចាំបាច់ត្រូវបានការពារធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់សុវត្ថិភាព និងសន្តិសុខរបស់កុមារ ឬធ្វើឱ្យកុមារត្រូវប្រឈមហានិភ័យនៃគ្រោះថ្នាក់ឬការមាក់ងាយ។

៣. ព្រះសង្ឃ ឬអ្នកមើលថែត្រូវបានដឹងអំពីរបៀបដាក់ពិន័យបែបវិជ្ជមានហើយត្រូវបានហាមឃាត់មិនឱ្យ ប្រើប្រាស់ការដាក់ទណ្ឌកម្ម ដែលអាចបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្នែករាងកាយខួរក្បាល ផ្លូវចិត្ត និងផ្នែកសង្គមរបស់កុមារឡើយ។ ឧទាហរណ៍ ការពិន័យណាមួយដូចខាងក្រោមនេះគឺត្រូវហាមឃាត់ដាច់ខាត៖

- ការចាក់សោរកុមារបង្ខាំងឱ្យនៅតែឯង
- ការចងកុមារ
- ការរារាំងកុមារមិនឱ្យទៅសាលា
- ការដកហូតមិនឱ្យញ៉ាំអាហារ ផឹកទឹក ឬគេង[8]
- តម្រូវឱ្យកុមារស្លៀកពាក់ខុសប្លែក ឬសម្លៀកបំពាក់មិនសមរម្យ
- ដកហូតការព្យាបាលផ្នែកវេជ្ជសាស្ត្រ
- ការប្រើប្រាស់កុមារឱ្យដាក់ពិន័យកុមារដទៃទៀត

[8] មិនរួមបញ្ចូលការមិនផ្តល់អាហារក្រោយម៉ោង ១២ ថ្ងៃត្រង់សម្រាប់នេន ដោយយោងទៅតាមច្បាប់ពុទ្ធសាសនា។

- ស្តីបន្ទោសកុមារដោយប្រើប្រាស់ពាក្យគ្រោតគ្រាត និងអាសគ្រាម

៤. ព្រះសង្ឃ និងអ្នកមានទំនាក់ទំនងជាមួយវត្ត ឬរស់នៅក្នុងវត្តត្រូវបានហាមឃាត់មិនឱ្យបង្ហោះ ប្រើប្រាស់ចូលទៅបើកមើល ឬចែកចាយរូបភាពឬសម្ភារៈអាសអាភាសកុមារ រូបភាពកុមាររងការរំលោភបំពាន ឬប្រាស្រ័យទាក់ទងសារដែលមានលក្ខណៈផ្លូវភេទស្តែងចេញយ៉ាងច្បាស់នោះឡើយ។

៥. វត្តមិនគួរទទួលយកការចូលរួមវិភាគទាន ឬទិញផលិតផល ឬសេវាពីក្រុមហ៊ុន ឬបុគ្គលណាដែលជួលកុមារឱ្យធ្វើការដោយរំលោភទៅលើច្បាប់ជាតិពាក់ព័ន្ធជាមួយពលកម្មកុមារ ឬនៅក្រោមស្ថានភាព ឬលក្ខខណ្ឌដែលបង្កើតឱ្យមានពលកម្មកុមារដែលត្រូវបានហាមឃាត់ ដូចបានកំណត់ខាងលើឡើយ។

៦. វត្តគួរទទួលស្គាល់ថា កុមាររស់នៅក្នុងតំបន់រងផលប៉ះពាល់ដោយបញ្ហាអាសន្នមិនថា ជាបញ្ហាធម្មជាតិ ឬជម្លោះក្តីគឺមានភាពងាយរងគ្រោះជាពិសេសចំពោះអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច។ វត្តត្រូវធានាឱ្យបានថា រាល់សកម្មភាពឆ្លើយតបគ្រោះមហន្តរាយ គួរត្រូវបានធ្វើឡើងអនុលោមតាមគោលនយោបាយនេះ ហើយជានិច្ចកាលត្រូវពិចារណានិងយកចិត្តទុកដាក់អំពីហានិភ័យចំពោះកុមារនៅពេលបង្កើតសកម្មភាពឆ្លើយតបគ្រោះមហន្តរាយ។

៧. ស្របពេល ដែលវត្តអារាមដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការថែទាំជំនួសតាមសហគមន៍ ព្រះសង្ឃគួរដើរតួនាទីជាអ្នកជំរុញឱ្យអាទិភាពលើការថែរក្សាកុមារតាមសហគមន៍ ជាជាងយកកុមារទៅដាក់ក្នុងមណ្ឌល។ ជាញឹកញាប់វត្តអារាមផ្តល់ការថែទាំដល់កុមារដែលត្រូវការការពារពិសេសប៉ុន្តែក្នុងករណីនេះការយកចេញពីគ្រួសារមកថែរក្សានៅក្នុងវត្តត្រូវជាជម្រើសចុងក្រោយ និងបណ្តោះអាសន្នតែប៉ុណ្ណោះ។ ក្នុងករណីដែលការបើកមណ្ឌលថែទាំកុមារនៅក្នុងវត្តជាសកម្មភាពសមស្របវត្តចាំបាច់ត្រូវអនុវត្តតាមគោលនយោបាយ និងបទដ្ឋានអប្បបរមារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការថែទាំជំនួស។

## ៦. ការចាត់តាំងជនបង្គោលការពារសុវត្ថិភាពកុមារតាមវត្តអារាម៖

វត្តទាំងអស់ ត្រូវចាត់តាំងឱ្យមានជនបង្គោលការពារសុវត្ថិភាពកុមារម្នាក់ ដែលមានការតួនាទី និងភារកិច្ច និងអនុលោមតាម “នីតិវិធីរាយការណ៍” ដូចមានចែងក្នុងគោលនយោបាយដូចខាងក្រោម ៖

- ទទួលពាក្យបណ្តឹងឬការរាយការណ៍អំពីករណីសង្ស័យអំពើហិង្សា ឬការរំលោភបំពានលើកុមារ និងដើម្បីប្រមូលព័ត៌មានពិតប្រាកដអំពីករណីកើតហេតុនោះ។
- ធ្វើការយ៉ាងជិតស្និទ្ធិជាមួយព្រះចៅអធិការដើម្បីផ្តល់ប្រឹក្សា និងអនុម័តលើសកម្មភាពឆ្លើយតប និងដើម្បីធានាឱ្យមានសកម្មភាពសមស្របនិងទាន់ពេលវេលាលើករណីនោះ។

- ផ្តល់ ឬធានាឱ្យមានការគាំទ្រចំពោះជនដែលសង្ស័យថាជាជនរងគ្រោះ និងគ្រួសាររបស់គេ ដូចជាការប្រឹក្សាយោបល់ អាហារ និងជម្រកសុវត្ថិភាពបណ្តោះអាសន្ន។ល។
- បំពេញរបាយការណ៍ករណីកើតហេតុ ចំពោះគ្រប់ករណីដែលបានរាយការណ៍។ ការងារនេះចាំបាច់ត្រូវធ្វើឡើងនៅក្នុងដំណើរការឆ្លើយតបទាំងមូល ចាប់តាំងពីបានទទួលពាក្យបណ្តឹងរហូតដល់មានដំណោះស្រាយឬការបញ្ជូន។
- រៀបចំរបាយការណ៍សង្ខេបតាមដំណាក់កាល រួមទាំងព័ត៌មានស្តីអំពីកុមារកំពុងរស់នៅក្នុងវត្ត និងរបាយការណ៍ស្តីពីករណីកើតហេតុអំពើហិង្សានិងការរំលោភបំពានលើកុមារ និងសកម្មភាពដែលត្រូវបានធ្វើឡើង ហើយត្រូវចែករំលែករបាយការណ៍ជាមួយចៅអធិការនិងព្រះអនុគណ។

ជនបង្គោលការពារសុវត្ថិភាពកុមារ ក៏ត្រូវរៀបចំវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី: គោលនយោបាយការពារសុវត្ថិភាពកុមារ និងក្រមសីលធម៌នៅក្នុងវត្តអារាម ផ្តល់ប្រឹក្សាដល់អ្នកដើរតួនាទីដទៃទៀតនៅក្នុងការទទួលខុសត្រូវក្នុងការរាយការណ៍ និងពិនិត្យតាមដានការអនុវត្តគោលនយោបាយបន្ថែមលើនេះទៀត ជនបង្គោលត្រូវចូលរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងដល់សហគមន៍ និងសកម្មភាពពង្រឹងសមត្ថភាពដើម្បីជំរុញកិច្ចការពារកុមារ។

## ៧. ការរាយការណ៍អំពីបញ្ហាកុមារដែលកើតមានក្នុងវត្តអារាម

វត្តទាំងអស់ត្រូវធ្វើការប្រមូលព័ត៌មាន និងតាមដានបន្តលើកង្វល់ ឬបញ្ហាកុមារ ហើយមានភារកិច្ចត្រូវរាយការណ៍ករណីសង្ស័យអំពីការរំលោភបំពានកុមារ ឬការរំលោភមកលើកុមារក្នុងទម្រង់ដទៃទៀត។ ក្នុងករណី កង្វល់ស្តីអំពីអាកប្បកិរិយាប្រកបដោយហានិភ័យ កើតមានចំពោះមនុស្សពេញវ័យនៅក្នុងវត្តដោយក្នុងនោះ ការរំលោភបំពានធ្ងន់ធ្ងរលើកុមារនៅពុំទាន់កើតមាននៅឡើយ បញ្ហានេះអាចត្រូវដោះស្រាយ តាមរយៈសកម្មភាពដាក់ពិន័យសមស្របជាលក្ខណៈផ្ទៃក្នុង។ ប៉ុន្តែ ចំពោះគ្រប់ករណីសង្ស័យការរំលោភបំពានលើកុមារទាំងអស់ តម្រូវឱ្យអនុវត្តតាមយន្តការរាយការណ៍សម្រាប់វត្តអារាម (ឧបសម្ព័ន្ធទី២) និងទាន់ពេលវេលា ដូចមានពន្យល់ខាងក្រោម ។

នីតិវិធីទទួលស្គាល់ថា អាចមានជំហានផ្សេងៗពីរ ដែលចាំបាច់ត្រូវធ្វើឡើងចំពោះជនសង្ស័យជាជនល្មើសដែលជាព្រះសង្ឃ និងជាគ្រហស្ថ។ ទោះយ៉ាងណាក្តី ចាំបាច់ត្រូវប្រកាន់ខ្ជាប់តាមវិធានច្បាប់នៅគ្រប់ករណីទាំងអស់។ គ្រប់ករណីសង្ស័យការរំលោភបំពានលើកុមារ ដែលពាក់ព័ន្ធជាមួយព្រះសង្ឃ ព្រះចៅអធិការវត្តត្រូវរាយការណ៍ប្រគេនទៅព្រះអនុគណ ដើម្បីពិគ្រោះយោបល់និងសុំមតិយល់ស្របលើសកម្មភាពដែលត្រូវធ្វើបន្ថែមទៀត អនុលោមតាមច្បាប់ពុទ្ធសាសនា ក៏ដូចជាច្បាប់ជាតិ

ដើម្បីការពារឯកជនភាព សេចក្តីថ្លៃថ្នូរ និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់កុមារ ព្រះចៅអធិការវត្ត ត្រូវធានាយ៉ាងណារក្សាការសម្ងាត់របស់ជនរងគ្រោះជាកុមារ ដោយមិនត្រូវបញ្ចេញអត្តសញ្ញាណកុមារឱ្យ

គេស្គាល់ជាសាធារណៈឡើយ តាមរយៈការប្តូរឈ្មោះកុមារនិងការដាក់ឱ្យមើលឃើញមុខកុមារព្រាលៗ មើលមិនច្បាស់នូវ អត្តសញ្ញាណកុមារទាំងឡាយណាដែលត្រូវបានកំណត់ថា ជាជនរងគ្រោះនៃអំពើហិង្សា ការរំលោភបំពានឬការកេងប្រវ័ញ្ច។ ការហាមឃាត់នេះត្រូវនៅបន្តជាធរមាន បើទោះបីជាកុមារ ឬមនុស្សពេញវ័យដែលទទួលបន្ទុកថែទាំកុមារនោះដោយស្របច្បាប់ បានផ្តល់ការយល់ព្រម ឬជនណាម្នាក់ ឬទីភ្នាក់ងារដែលជាម្ចាស់លើរូបថតនោះ បានផ្តល់ការព្រមព្រៀងហើយក្តី។

## ជំហានដើម្បីរាយការណ៍ករណី

**ជំហានទី១៖** រាយការណ៍ទៅដល់ជនបង្គោលការពារសុវត្ថិភាពកុមារប្រចាំវត្ត នូវរាល់កង្វល់ទាំងឡាយណាអំពីសុវត្ថិភាពកុមារ ឬអំពីករណីសង្ស័យអំពើហិង្សាលើកុមារ ឬការរំលោភបំពានលើកុមារនៅក្នុងបរិវេណវត្ត។ ភ្លាមៗបន្ទាប់ពីបានទទួលរបាយការណ៍ ជនបង្គោលត្រូវប្រមូលព័ត៌មានពាក់ព័ន្ធទាំងអស់ដើម្បីបញ្ជាក់ឱ្យច្បាស់ដើម្បីជាមូលដ្ឋានសម្រាប់ការឆ្លើយតបសមស្រប។

- ក្នុងករណីដែលជនល្មើសសង្ស័យ គឺជាជនបង្គោលការពារសុវត្ថិភាពកុមារ គួររាយការណ៍អំពីករណីកើតហេតុទៅដល់ព្រះចៅអធិការវត្ត។
- ក្នុងករណីដែលជនល្មើសសង្ស័យ គឺជាព្រះចៅអធិការគួររាយការណ៍អំពីករណីសង្ស័យទៅដល់ព្រះអនុគណ។

**ជំហានទី២៖** ជនបង្គោលការពារសុវត្ថិភាពកុមារចាំបាច់ត្រូវរាយការណ៍ព័ត៌មាន (របាយការណ៍ករណីកើតហេតុ) ប្រគេនព្រះចៅអធិការ ឬសុំមតិប្រឹក្សា និង/ឬដើម្បីសុំការឯកភាពបញ្ជូនទៅថ្នាក់លើឱ្យចាត់ការ។ របាយការណ៍នេះ គួរត្រូវបានធ្វើឡើងដោយផ្ទាល់ចំពោះមុខ ឬតាមមធ្យោបាយណាក្តីដែលលឿនបំផុតនិងងាយស្រួលបំផុត ឧ.ដូចជា ធ្វើឡើងចំពោះមុខដោយផ្ទាល់តាមរយៈទូរស័ព្ទតាមរយៈ សារឬអ៊ីម៉ែល។ នៅពេលបានទទួលមតិប្រឹក្សា ឬការឯកភាពពីចៅអធិការហើយ ជនបង្គោលចាំបាច់ត្រូវធ្វើសកម្មភាពជាបន្ទាន់។ ក្នុងរយៈពេល៣៦ម៉ោង ជនបង្គោលរួមជាមួយដៃគូពាក់ព័ន្ធចាំបាច់ត្រូវគាំទ្រ ការថែទាំសុវត្ថិភាពនិងសន្តិសុខកុមារ គ្រួសារនិងសាក្សីជាបន្ទាន់ក្នុងកិច្ចសម្របសម្រួលជាមួយអ្នកផ្តល់សេវានិងត្រូវរាយការណ៍ត្រឡប់មកវិញ អំពីជំហាននានាដែលត្រូវបានធ្វើឡើង។ សកម្មភាពដែលអាចធ្វើឡើងបានមានដូចជា៖

- សកម្មភាពសម្រាប់ជនរងគ្រោះ នៅពេលអំពើហិង្សាត្រូវបានចាត់ទុកជារឿងតូចតាច (មិនផ្ទុយជាមួយច្បាប់) ៖ នៅពេលកង្វល់ត្រូវបានរាយការណ៍អំពីករណីដូចជា ករណីពាក់ព័ន្ធជាមួយ ស្ថានភាពមានហានិភ័យ ការធ្វើបាប ការរំលោភបំពានផ្លូវចិត្ត ឬការរំលោភបំពានផ្លូវកាយជា ការដាក់ទណ្ឌកម្ម/ដាក់ពិន័យ ដោយពុំមានរបួសស្នាមទេនោះ សកម្មភាពអាចត្រូវបានធ្វើឡើងដោយ ព្រះចៅអធិការ

នៅក្នុងវត្ត ដោយមានអាចារ្យនិងគណៈកម្មាការវត្តនិង/ឬក្នុងកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាការ ទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារឃុំសង្កាត់និង NGOs ដើម្បីគាំទ្រក្នុងការឆ្លើយតបបញ្ហានេះ។

- សកម្មភាពសម្រាប់ជនរងគ្រោះនៅពេលការរំលោភបំពានមានលក្ខណៈធ្ងន់ធ្ងរ ផ្ទុយជាមួយច្បាប់៖ ផ្អែកលើតម្រូវការចំពោះមុខរបស់ជនរងគ្រោះនិងលក្ខណសម្បត្តិនៃការរំលោភបំពាននោះចាំបាច់ត្រូវបញ្ជូនករណីបន្តទៅឱ្យអ្នកផ្តល់ការថែទាំសុខភាព សម្រាប់ការគាំទ្រផ្នែកសុខភាពបញ្ជូនទៅអង្គការមិនមែនរដ្ឋាភិបាល ការិយាល័យឬនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាចំពោះការគាំទ្រផ្នែកសង្គមកិច្ច រួមទាំងការវាយតម្លៃសេចក្តីត្រូវការផ្សេងទៀតរបស់កុមារ និងការប្រឹក្សាយោបល់និង/ ឬទៅដល់គណៈកម្មាការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំសង្កាត់សម្រាប់ការគាំទ្រផ្នែកសហគមន៍។ ប្រសិនបើកុមារកំពុងរស់នៅជាមួយជនសង្ស័យជាអ្នករំលោភបំពាន ចាំបាច់ត្រូវការពារកុមារពីជនសង្ស័យជាសម្ងាត់ និងដោយមិនឱ្យជនសង្ស័យដឹងខ្លួនឡើយ។
- សកម្មភាពនៅពេលជនសង្ស័យរំលោភបំពានពុំមែន ព្រះសង្ឃ ឬអាចារ្យ ៖ ហាមឃាត់ជនសង្ស័យមិនឱ្យបន្តសកម្មភាពតទៅទៀតបាន។ ធ្វើការបញ្ជូនទៅឱ្យសេវាសង្គមកិច្ច NGOs និង/ឬអាជ្ញាធរមូលដ្ឋាន ឬនគរបាលយុត្តិធម៌ឱ្យធ្វើការស៊ើបអង្កេតនិងអនុវត្តនីតិវិធីយុត្តិធម៌ ដទៃទៀត។
- សកម្មភាពនៅពេលជនល្មើសដែលត្រូវបានសង្ស័យជាព្រះសង្ឃ ឬមន្ត្រីសង្ឃ ៖ ព្រះចៅអធិការត្រូវរាយការណ៍ករណីនោះជាបន្ទាន់ទៅ ព្រះអនុគណ ដើម្បីសុំយោបល់ស្តីពីវិធានការដែលគួរធ្វើឡើងទៅតាមបញ្ញត្តិពុទ្ធសាសនានិងអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន។

**ជំហានទី ៣ ៖** ព្រះចៅអធិការវត្តចាំបាច់ត្រូវរាយការណ៍ករណី និងសកម្មភាពដែលបានធ្វើឡើងទៅព្រះអនុគណ ដោយប្រើប្រាស់ទម្រង់រាយការណ៍អំពីករណីកើតហេតុ (ឧបសម្ព័ន្ធ៣)។ ក្នុងករណីដែលជនសង្ស័យគឺជាព្រះសង្ឃ ព្រះចៅអធិការចាំបាច់ត្រូវសុំការឯកភាពពី ព្រះអនុគណ ក្នុងការដាក់ពិន័យ ឬផ្សឹកជនសង្ស័យ ហើយប្រគល់ខ្លួនគាត់ទៅឱ្យអាជ្ញាធរមូលដ្ឋាន ឬនគរបាល។ នៅពេលបានទទួលការឯកភាពពីព្រះអនុគណហើយ ព្រះចៅអធិការវត្តចាំបាច់ត្រូវណែនាំដល់ជនបង្គោលឱ្យចាត់ការបន្ត។

- ក្នុងករណីអំពើហិង្សាធ្ងន់ធ្ងរលើកុមារ ដែលមិនអាចដោះស្រាយបានដោយព្រះអនុគណ (រួមទាំងការរំលោភបំពានផ្លូវភេទ ផ្លូវកាយ ការជួញដូរ ធ្ងន់ធ្ងរ។ល។) ព្រះអនុគណ ចាំបាច់ត្រូវរាយការណ៍ករណីនេះទៅ ព្រះមេគណ និងប្រធានមន្ទីរធម្មការ និងសាសនា ដើម្បីរាយការណ៍បន្តទៅ សម្តេចព្រះសង្ឃនាយក និងរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាប្រសិនបើចាំបាច់រដ្ឋមន្ត្រី និងសម្តេចព្រះសង្ឃនាយក អាចបង្កើតគណៈកម្មាធិការស៊ើបអង្កេតមួយ ដើម្បីស៊ើបអង្កេតលើករណីនេះ ឬដាក់ថ្វាយទៅថេរសភាសង្ឃ ដើម្បីសម្រេចដោះស្រាយចុងក្រោយនឹងបិទផ្លូវតវ៉ា។

# ជំពូកទី២
# កម្មវិធីវត្តសង្គហកុមារ

## ១. សេចក្ដីផ្ដើម

ដើម្បីធានា នូវសិទ្ធិជាមូលដ្ឋានរបស់កុមារតាមរយៈការអនុវត្តគោលនយោបាយវត្តសង្គហកុមារ ឬគោលនយោបាយកិច្ចការពារកុមារតាមវត្តអារាម ក្រសួងធម្មការ និងសាសនា សហការជាមួយគណៈសង្ឃនាយកទាំងពីរគណៈ ក្រោមការជួយគាំទ្រពីអង្គការយូនីសេហ្វ បានរៀបចំកម្មវិធីវត្តសង្គហកុមារ (ឬហៅថាកម្មវិធីកិច្ចការពារកុមារតាមវត្តអារាម)។ សៀវភៅបណ្ដុះបណ្ដាលស្ដីពីកម្មវិធីវត្តសង្គហកុមារ និងសម្ភារៈអប់រំមួយចំនួននឹងត្រូវរៀបចំនិងផលិតដោយឡែក ដើម្បីជាជំនួយស្មារតីដល់គ្រូបង្គោល និងប្រើប្រាស់ក្នុងការផ្សព្វផ្សាយ គោលនយោបាយវត្តសង្គហកុមារ ពង្រឹងសមត្ថភាពព្រះសង្ឃនឹងវត្ត ដើម្បីអនុវត្តន៍គោលនយោបាយនិងលើកកម្ពស់ការយល់ ដឹងយល់ដឹងដល់សហាគមន៍ក្នុងបង្កើតនូវបរិយាកាស កិច្ចការពារកុមារទាំងនៅក្នុងវត្តនិងសហាគមន៍។

គុណតម្លៃរួម នៃកិច្ចការពារកុមារជាមូលដ្ឋានដ៏ខ្លាំងក្លា មិនត្រឹមតែចំពោះការប្ដេជ្ញាចិត្តតែ ប៉ុណ្ណោះទេក៏ប៉ុន្តែសម្រាប់សកម្មភាពរួមគ្នាផងដែរ។ ចាប់ពីឆ្នាំ២០០៧មក តាមរយៈគម្រោងការផ្ដួចផ្ដើមគំនិតភាពជាអ្នកដឹកនាំពុទ្ធសាសនា នៃក្រសួងធម្មការនិងសាសនា បានសហការជាមួយអង្គការយូនីសេហ្វ ដើម្បីគាំទ្រដល់ព្រះសង្ឃពុទ្ធសាសនាក្នុងកិច្ចការពារកុមារ និងក្រុមគ្រួសារកុមារដែលរងផលប៉ះពាល់ពីមេរោគអេដស៍និងជំងឺអេដស៍។ អនុសាសន៍មួយ ពីការវាយតម្លៃលើគម្រោងការផ្ដួចផ្ដើមគំនិតភាពជាអ្នកដឹកនាំពុទ្ធសាសនា ឆ្នាំ២០០៨-២០១២ គឺចាប់យកឱកាសដើម្បីបង្កើនចំណេះដឹងដល់ព្រះសង្ឃអំពីកិច្ចការពារកុមារ ក៏ដូចជាបង្កើនការយល់ដឹងអំពីការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិកុមារ ទាំងនៅកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់និងនៅតាមវត្តអារាម។

ដោយហេតុនេះ ក្នុងឆ្នាំ២០១៣ គម្រោងបានពង្រីកបន្ថែម ឈានទៅផ្ដោតការយកចិត្តទុកដាក់លើអំពើហិង្សាលើកុមារ និងអត្ថប្រយោជន៍នៃការគាំទ្រកុមាររស់នៅក្នុងគ្រួសារ។ គោលបំណងរបស់គម្រោងនេះ គឺដើម្បីគាំទ្រមេដឹកនាំព្រះពុទ្ធសាសនា ព្រមទាំងអំណាចផ្នែកសីលធម៌របស់ព្រះអង្គឱ្យក្លាយជាអ្នកតស៊ូមតិសម្រាប់កុមារ និងគាំទ្រឱ្យមានការផ្លាស់ប្ដូរនិយាម និងអាកប្បកិរិយាសង្គមទាំងឡាយណាដែលបង្កគ្រោះថ្នាក់ចំពោះកុមារ។ ក្នុងឆ្នាំ២០១៤ និង២០១៥ ក្រសួងធម្មការ និងសាសនា បានសហការជាមួយអង្គការយូនីសេហ្វ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់អន្តរសាសនាស្ដីពី“ការការពារកុមារ”ផលិតឯកសារព័ត៌មាននិងរៀបចំទិវាពិភពលោកសកម្មភាពដើម្បីកុមារ (DPAC)

ដែលជាមូលដ្ឋានសម្រាប់បង្កើនសកម្មភាពកាន់តែច្រើនឡើងថែមទៀត។ សំណើដ៏សំខាន់មួយដែលទទួលបានពីសិក្ខាសាលាក្នុងឆ្នាំ២០១៥ គឺត្រូវអភិវឌ្ឍកម្មវិធីការពារកុមារមួយសម្រាប់បរិយាកាសសាសនា (វត្ត អារាម ព្រះវិហារឥស្លាមនិងព្រះវិហារគ្រិស្តសាសនា)។ ក្រសួងធម្មការ និងសាសនា បានសហការជា មួយ អង្គការយូនីសេហ្វ សម្រេចចិត្តចាប់ផ្តើមការងារដោយផ្តោតការយកចិត្តទុកដាក់លើវត្តអារាមពុទ្ធសាសនា រួចបន្តអនុវត្តឈានទៅដល់សាសនាធំៗដទៃទៀត ក្នុងប្រទេសកម្ពុជាផ្អែកលើមេរៀនជាបទពិសោធន៍ដែលទទួលបាន។

អត្ថិភាពសម្រាប់ឆ្នាំ ២០១៧-២០១៨ គឺបង្កើតនិងអនុវត្តកម្មវិធីកិច្ចការពារកុមារតាមវត្តអារាម ឬ **វត្តសង្គហកុមារ**[9] សម្រាប់កិច្ចការពារកុមារតាមរយៈការពង្រឹង ការបង្ការនិងការឆ្លើយតបចំពោះអំពើហិង្សាលើកុមារតាមវត្តអារាមនិងក្នុងសហគមន៍ និងបង្កើតបរិយាកាសការពារកុមារ តាមរយៈការគាំទ្រកុមាររស់នៅក្នុងគ្រួសាររបស់ពួកគេ។ កម្មវិធីនេះត្រូវបានតាក់តែងឡើងបន្ទាប់ពីមានការពិគ្រោះយោបល់ជាច្រើនដងនិងស៊ីជម្រៅជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់របស់ពុទ្ធសាសនា ព្រះសង្ឃ អ្នកសិក្សាស្រាវជ្រាវ និងអ្នកតំណាងក្រសួងធម្មការ និងសាសនា។ កម្មវិធីនេះក៏ឆ្លើយតបចំពោះអនុសាសន៍មួយចំនួនបានមកពី "ការសិក្សាស្តីពីការថែទាំជំនួស ការអនុវត្តនៅសហគមន៍សម្រាប់កុមារក្នុងប្រទេសកម្ពុជា រួមទាំងក្នុងវត្តអារាម"[10] ឆ្នាំ២០១៧ ដែលលើកឡើងគួរជាទីកត់សម្គាល់ថា "ក្រសួងធម្មការ និងសាសនាគួរអនុវត្តគោលនយោបាយការពារកុមារ គំរូមួយសម្រាប់វត្តអារាម និងកែសម្រួលក្រមសីលធម៌សម្រាប់វត្តអារាម/ព្រះសង្ឃ"។ អនុសាសន៍នេះក៏ផ្តល់មូលដ្ឋានសម្រាប់អនុសាសន៍ដទៃទៀតដូចជា "ក្រសួងធម្មការ និងសាសនា និងក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា គួរអភិវឌ្ឍឱ្យមានទម្រង់ការធ្វើការងាររួមគ្នាស្តីពីការទទួលខុសត្រូវចំពោះកុមារក្នុងវត្តអារាម និងវត្តអារាមគួរត្រូវបានតម្រូវឱ្យជម្រាបប្រាប់ទៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាថ្នាក់ស្រុក (DOSVY) អំពីការទទួលយកកុមារណាម្នាក់ចូលមករស់នៅក្នុងករណីដែលការការពារកុមារ គឺជាមូលហេតុទាំងស្រុង ឬមូលហេតុមួយផ្នែកធ្វើឱ្យមានការទទួលយកកុមារមកស្នាក់នៅ រួមទាំងចំណាកស្រុករបស់ឪពុកម្តាយ ការស្លាប់

---

[9] ឈ្មោះកម្មវិធីដោយពាក្យវត្តសង្គហកុមារត្រូវបានណែនាំឱ្យប្រើដោយសម្តេចព្រះអគ្គមហាសង្ឃរាជ ទេព វង្ស ក្នុងបំណងដើម្បីឱ្យព្រះសង្ឃផ្តល់ការអប់រំដល់កុមារ។ អត្ថន័យរបស់ពាក្យនេះមានលក្ខណៈទូលំទូលាយថែមទៀតដើម្បីផ្តល់ការការពារដល់កុមារ។ យើងផ្តល់ការបកប្រែបែបទូលាយមកជាភាសាខ្មែរថា "កិច្ចការពារកុមារតាមវត្តអារាម" ដើម្បីគ្របដណ្តប់លើអត្ថន័យតាមន័យទូលាយរបស់កិច្ចការពារ កុមារ។

[10] Hamilton C., etal - Study on Alternative Care Community Practices for Children in Cambodia, Including Pagoda Based Care, 2017 ចាត់បេសកកម្មដោយអង្គការយូនីសេហ្វកម្ពុជា ក្នុងកិច្ចសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា

ការរៀបការឡើងវិញ និងការបដិសេធមិនព្រមមើលថែកុមារនោះ ឬការរំលោភបំពាន ការមិនអើពើ ឬអំពើហិង្សាក្នុងទម្រង់ណាមួយ”។

ឯកសារនេះគូសបញ្ជាក់អំពីស្ថានភាពនៃកិច្ចការពារកុមាររួមទាំងនៅតាមវត្តអារាមសនិទានភាពសម្រាប់ការបង្កើតឱ្យមានកម្មវិធីវត្តសង្គហកុមារ និងការតាក់តែងកម្មវិធីនិងផែនការអនុវត្ត។

## ២. សាវតារ និងស្ថានភាព

អំពើហិង្សាលើកុមារ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយក្នុងប្រទេសទាំងអស់ ដូចបានរាយការណ៍នៅក្នុងរបាយការណ៍ពិភពលោកស្តីពីអំពើហិង្សាលើកុមារ[11] របស់អគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិឆ្នាំ២០០៦ និងនៅក្នុងការសិក្សាតាមដានបន្តឆ្នាំ២០១៤ ដែលមានចំណងជើងថា "ការលាក់បំពួនក្រោមក្រសែភ្នែកទទេ"[12] (Hidden in Plain Sight)។ ថ្វីបើទម្រង់មួយចំនួននៃអំពើហិង្សាគឺជាអំពើហិង្សាទម្រង់ថ្មីៗ និងទើបកើតមានជាលទ្ធផលនៃស្ថេរភាពកាន់តែច្រើនឡើង ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងលទ្ធភាពទទួលបានបច្ចេកវិទ្យាថ្មីៗក្តី ប៉ុន្តែអំពើហិង្សាលើកុមារភាគច្រើនគឺចាក់ឫសយ៉ាងជ្រៅនៅក្នុងជំនឿ និងការអនុវត្តបែបប្រពៃណីប្រកបដោយគ្រោះថ្នាក់។

ការរកឃើញពីការស្ទាបស្ទង់មតិអំពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា (CVACS)[13]ធ្វើឡើងក្រោមកិច្ចដឹកនាំរបស់រដ្ឋាភិបាលក្នុងឆ្នាំ២០១៣ ដោយបានទទួលការគាំទ្រពីយូនីសេហ្វបង្ហាញថាអំពើហិង្សាគឺជាបញ្ហាគួរជាទីកត់សម្គាល់មួយក្នុងកុមារភាពសម្រាប់កុមារកម្ពុជា។ ការរកឃើញសំខាន់ៗរួមមាន៖

- ជាង៥០% នៃកុមារដែលបានចូលរួមនៅក្នុងការសិក្សាបានជួបបទពិសោធន៍អំពើហិង្សាយ៉ាងហោចណាស់មួយទម្រង់មុនពេលឈានចូលដល់អាយុ១៨ ឆ្នាំ។
- អំពើហិង្សាផ្នែករាងកាយគឺជាប្រភេទអំពើហិង្សា ដែលត្រូវបានរាយការណ៍ញឹកញាប់ជាងគេបំផុតឆ្លងកាត់ដោយអ្នកផ្តល់ចម្លើយ ហើយជាង៨០% នៃអ្នកមានអាយុ១៨ ដល់២៤ ឆ្នាំធ្លាប់ជួបករណីអំពើហិង្សាផ្នែករាងកាយច្រើនដង។
- ប្រមាណ៥% ទៅ៦% នៃបុរសនិងស្ត្រីបានរាយការណ៍ថាធ្លាប់មានបទពិសោធន៍ យ៉ាងហោចណាស់ម្តងជាមួយការរំលោភបំពានផ្លូវភេទមុនពេលអាយុ១៨ឆ្នាំ ហើយក្នុងចំណោមអ្នកអាយុ

---

[11] Pinheiro PS, UN World Report on Violence against Children, Geneva, Switzerland, 2006

[12] United Nations Children's Fund, Hidden in Plain Sight: A statistical analysis of violence against children, UNICEF, New York, 2014.

[13] Cambodia: Ministry of Women's Affairs, UNICEF Cambodia, US Centers for Disease Control and Prevention Cambodia's Violence against Children Study 2013

១៨ ដល់ ២៤ឆ្នាំ ប្រមាណ៧នាក់ក្នុងចំណោមស្ត្រី១០ និងជិត៩នាក់ ក្នុងចំណោមបុរស១០ នាក់ធ្លាប់មានបទពិសោធន៍ជួបករណីការរំលោភបំពានផ្លូវភេទច្រើនដង។

- ឪពុកម្តាយ អ្នកថែទាំនិងសមាជិកជាមនុស្សពេញវ័យដទៃទៀតក្នុងគ្រួសារនិងគ្រូបង្រៀនគឺជាជនល្មើសភាគច្រើនបំផុតនៃអំពើហិង្សាផ្លូវកាយលើកុមារ។
- អ្នកជិតខាង សមាជិកគ្រួសារ មិត្តភក្តិ និងដៃគូណាត់ជួបគឺជាជនល្មើសដែលត្រូវបានលើកឡើងញឹកញាប់ជាងគេបំផុតនៃករណីការរំលោភបំពានផ្លូវភេទលើកុមារ។

ជាង៩០% នៃប្រជាជនកម្ពុជាគឺជាពុទ្ធសាសនិក។ វត្តពុទ្ធសាសនាគឺជាទីប្រជុំជាប្រក្រតីរបស់សហគមន៍ ហើយបានផ្តល់ការអប់រំនិងសេវាពាក់ព័ន្ធជាមួយសុខភាពជាច្រើន ក៏ដូចជាការថែទាំចំពោះគ្រួសារក្រីក្រអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ក្នុងឆ្នាំ២០១៦ មានការរាយការណ៍ថាមានវត្តចំនួន ៤.៨៧២វត្ត ទូទាំងប្រទេសកម្ពុជា និងព្រះសង្ឃប្រមាណ ៦៩.១៩៩អង្គ។[14] ព្រះសង្ឃត្រូវបានគេមើលឃើញថាជាអ្នកកំណត់បទដ្ឋានសីលធម៌ ហេតុនេះហើយព្រះអង្គមានឱកាសជះឥទ្ធិពលលើជំនឿ និងអាកប្បកិរិយាសង្គម។

ជាទូទៅ វត្តអារាមត្រូវបានប្រជាជនកម្ពុជាមើលឃើញថាជាទីកន្លែងមានសុវត្ថិភាពសម្រាប់កុមារ វត្តធំៗមួយចំនួនផ្តល់ជម្រើសជំនួសឱ្យប្រព័ន្ធអប់រំរដ្ឋាភិបាល សម្រាប់គ្រួសារមានជីវភាពក្រីក្រខ្លាំង។ វត្តស្ទើរទាំងអស់ ផ្តល់ការគាំទ្រជាវត្ថុ ដូចជាម្ហូបអាហារជាដើម ដើម្បីលើកទឹកចិត្តឪពុកម្តាយឱ្យបញ្ជូនកូនទៅសាលារៀន និងកុំឱ្យពួកគេត្រូវធ្វើការ ហើយវត្តជាច្រើនផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារដែលពុំមានជម្រើសការថែទាំដទៃទៀតនៅតាមគ្រួសារ។ យោងតាមការរកឃើញពីការធ្វើផែនទីមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា[15] របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា (MoSVY) ក្នុងឆ្នាំ ២០១៧ បានឱ្យដឹងថា១១% នៃមណ្ឌលថែទាំកុមារគឺជាមណ្ឌលពុទ្ធសាសនា ដោយទទួលស្គាល់ថាប្រហែលជាអាចមានមណ្ឌលច្រើនជាងនេះទៀតក្នុងចំណោមគ្រឹះស្ថានថែទាំទាំង៦៥ ដែលពុំត្រូវបានចាត់ប្រភេទជាលក្ខណៈសាសនា។ បន្ថែមលើនេះទៀត ប្រពៃណីស្តីពីវ័យដែលកំណត់ថាក្មេងប្រុសអាយុក្រោម២០ឆ្នាំត្រូវចូលវត្តបួសជាសាមណេរ លើ២០ឆ្នាំបួសជាភិក្ខុបានផ្តល់លទ្ធផលឱ្យមានក្មេងប្រុសរាប់ពាន់នាក់រស់នៅក្រោមការចង្អុលបង្ហាញរបស់ព្រះសង្ឃនៅក្នុងវត្តអារាម។ភាគច្រើនពួកគេស្នាក់នៅក្នុងវត្ត រយៈពេលតិចជាងមួយឆ្នាំមុនពេលវិលត្រឡប់ទៅរស់នៅក្នុងគ្រួសារវិញ។ មានការប៉ាន់ប្រមាណថា ៥០% នៃព្រះសង្ឃចំនួន ៦៩.១៩៩អង្គ ក្នុងប្រទេសកម្ពុជាគឺជាកុមារ។

---

[14] Ministry of Cults and Religion, List of pagodas and monks in 25 municipality and provinces 2016-2017

[15] Cambodia: Ministry of Social Affairs, Veterans and Youth Rehabilitation, Mapping of Residential Care Facilities in Cambodia 2017

ថ្វីបើទទួលស្គាល់អំពីតួនាទីដ៏សំខាន់របស់វត្តអារាមក្នុងការគាំទ្រដល់កុមារកំព្រា និងកុមារងាយរងគ្រោះដទៃទៀតក្នុងប្រទេសកម្ពុជា និងក្នុងការផ្តល់ការអប់រំនិងការបណ្តុះបណ្តាលផ្នែកសាសនាដល់សាមណេរក្មេងៗក្តី ប៉ុន្តែមានការទទួលស្គាល់កាន់តែច្រើនថា ដោយមានបរិយាកាសរស់នៅប្រមូលផ្តុំគ្នាក្នុងស្ថាប័នសម្រាប់កុមារ កង្វះយន្តការផ្លូវការដើម្បីការពារកុមារក្នុងវត្តអារាមដែលមានបញ្ហាអំពើហិង្សា និងការរំលោភបំពានលើកុមារឱ្យនៅលាក់បាំង ហើយពុំត្រូវបានឆ្លើយតបគ្រប់គ្រាន់។ ការពង្រឹងកិច្ចការពារកុមាររស់នៅក្នុងវត្តអារាមដោយ គោលនយោបាយនីតិវិធី និងគោលការណ៍ណែនាំការពារសុវត្ថិភាពកុមារយ៉ាងតឹងរ៉ឹង និងយន្តការមានលក្ខណៈជាប្រព័ន្ធក្នុងការរាយការណ៍ និងឆ្លើយតបចំពោះករណីរំលោភបំពានមិនត្រឹមតែអាចឆ្លើយតបបញ្ហានៅក្នុងវត្តអារាមបានតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងអាចផ្តល់ ឱកាសដើម្បីអប់រំគ្រួសារ និងសហគមន៍បានផងដែរ។

អ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួន បានបង្ហាញក្តីបារម្ភថាដើម្បីឱ្យព្រះសង្ឃ អាចផ្សារភ្ជាប់ជាមួយ សហគមន៍បានកាន់តែប្រសើរ ព្រះសង្ឃចាំបាច់ត្រូវយល់អំពីបញ្ហាថ្មីៗ និងបញ្ហាកំពុងលេចឡើង រួមទាំងសម្ពាធដែលមនុស្សវ័យជំទង់ និងយុវជនជួបប្រទះក្នុងសង្គមដែលកំពុងមានការប្រែប្រួលឥតឈប់ឈរនេះ។ ពួកគាត់ក៏យល់ឃើញថាព្រះសង្ឃក្នុងប្រទេសកម្ពុជាត្រូវការជំនាញ និងការបណ្តុះបណ្តាលអំពីវិធីដើម្បី "បកស្រាយ" គោលការណ៍ពុទ្ធសាសនាទៅអនុវត្តក្នុងកង្វល់ប្រចាំថ្ងៃពាក់ព័ន្ធជាមួយកុមារ ឧ. តាមរយៈការប្រើប្រាស់រឿងនិទានក្នុងពុទ្ធសាសនា ឬឧទាហរណ៍ផ្សេងៗ។

## ៣. កម្មវិធី

កម្មវិធីវត្តសង្គហកុមារ ឬកិច្ចការពារកុមារតាមវត្តអារាមត្រូវបានអភិវឌ្ឍឡើងជាផ្នែកមួយនៃការអនុវត្តគោលនយោបាយវត្តសង្គហកុមារ ដើម្បីធ្វើឱ្យវត្តអារាម និងសហគមន៍កាន់តែមានសុវត្ថិភាពសម្រាប់កុមាររួចផុតពីអំពើហិង្សា និងការរំលោភបំពាន និងដើម្បីពង្រឹងជំនាញរបស់ព្រះសង្ឃនៃពុទ្ធសាសនា ឱ្យលើកកម្ពស់ការយល់ដឹង និងអប់រំសហគមន៍អំពីការទប់ស្កាត់អំពើហិង្សាលើកុមារ និងអត្ថប្រយោជន៍នៃការគាំទ្រកុមារឱ្យរស់នៅក្នុងគ្រួសារ។

ដោយមានគោលដៅទូទៅដើម្បី បង្កើនការសម្រេចបានសិទ្ធិកុមារក្នុងប្រទេសកម្ពុជាឱ្យទទួលបានការការពារពីអំពើហិង្សានិងការរំលោភបំពាន "កម្មវិធីវត្តសង្គហកុមារ" មានគោលបំណងជាក់លាក់ចំនួនបួន។ គោលបំណងជាក់លាក់ទាំងនោះមាន៖

- ធ្វើឱ្យវត្តអារាម និងសហគមន៍កាន់តែមានសុវត្ថិភាពសម្រាប់កុមារា កុមារី និងក្មេងជំទង់រួចផុតពីអំពើហិង្សានិងការរំលោភបំពាន។

- បង្កើតប្រព័ន្ធសព្វជ្រុងជ្រោយសម្រាប់រាយការណ៍ និងឆ្លើយតបចំពោះករណីសង្ស័យការរំលោភបំពាននៅក្នុងវត្តអារាម។
- កសាងសមត្ថភាពព្រះសង្ឃឱ្យធ្វើការតស៊ូមតិ លើកកម្ពស់ការយល់ដឹងនិងផ្តល់ការប្រឹក្សាយោបល់ក្នុងសហគមន៍ដើម្បីទប់ស្កាត់អំពើហិង្សាលើក្មេងស្រី ក្មេងប្រុស និងមនុស្សវ័យជំទង់ ព្រមទាំងអត្ថប្រយោជន៍នៃការគាំទ្រកុមារឱ្យរស់នៅជាមួយគ្រួសារ។
- ការតាក់តែងកម្មវិធីបានពិចារណាលើរចនាសម្ព័ន្ធ ការទទួលខុសត្រូវនិងសកម្មភាពរបស់វត្តអារាម ក៏ដូចជារបស់ក្រសួងធម្មការនិងសាសនានិងគណៈសង្ឃ (ក្រុមប្រឹក្សាសង្ឃ) ដែលមានមុខងារដឹកនាំសម្រាប់វត្តអារាម។

## ៣.១. សមាសធាតុកម្មវិធី

កម្មវិធីការពារកុមារតាមវត្តអារាមមានសមាសធាតុសំខាន់ៗបី ដោយសមាសធាតុទាំងអស់មានភាពត្រួតស៊ីគ្នា និងគាំទ្រឱ្យគ្នាទៅវិញទៅមក។ គោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាមអាចបំពេញមុខងារបានតែនៅពេលមានការបណ្តុះបណ្តាល និងការកសាងសមត្ថភាពបានគ្រប់គ្រាន់សម្រាប់ព្រះសង្ឃ ដើម្បីអាចផ្តល់ព័ត៌មានចាំបាច់គ្រប់គ្រាន់ឱ្យព្រះអង្គអាចធ្វើការលើកកម្ពស់ការយល់ដឹង និងអាចក្លាយជាជនគំរូនៃអាកប្បកិរិយាដែលមានសុវត្ថិភាព និងសមស្របជាមួយកុមារ ទាំងនៅក្នុងវត្ត និងនៅក្នុងសហគមន៍។ សកម្មភាពពិនិត្យតាមដាន និងរាយការណ៍ផ្តល់ព័ត៌មានស្តីពីស្ថានភាពនិងវឌ្ឍនភាពរួមទាំងអំពីលក្ខខណ្ឌវិនិច្ឆ័យ ដើម្បីទទួលបានមេដាយ និងវិញ្ញាបនបត្រជាវត្តសង្គហកុមារ ព័ត៌មានប្រមូលបានក៏អាចក្លាយជាមូលដ្ឋានគ្រឹះ សម្រាប់ការធ្វើសកម្មភាពដែលចាំបាច់ដើម្បីកែលម្អការអនុវត្តឱ្យកាន់តែប្រសើរឡើងផងដែរ។

### ៣.១.១. ការអនុវត្តគោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម

- អនុម័តលើគោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម
- ចាត់តាំងជនបង្គោលទទួលបន្ទុកសុវត្ថិភាពកុមារ
- ប្រមូលព័ត៌មាន និងពិនិត្យតាមដានបន្តលើករណីការរំលោភបំពាន/វិវាទនិងពាក្យបណ្តឹង
- រាយការណ៍ករណីអំពើហិង្សាលើកុមារ ទាំងផ្ទៃក្នុង និងទៅខាងក្រៅ

#### គោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម

ជំហានដំបូង គឺត្រូវឱ្យវត្តនីមួយៗ អនុម័តឱ្យមានគោលនយោបាយការពារសុវត្ថិភាពកុមារ។ គោលនយោបាយការពារសុវត្ថិភាពកុមារ ត្រូវបានអភិវឌ្ឍឡើងផ្អែកលើការអនុវត្តល្អកម្រិតសកល ហើយ

ពិចារណា លើគោលការណ៍ដ៏ជាក់លាក់នៅក្នុងពុទ្ធសាសនា និងរចនាសម្ព័ន្ធក្នុងប្រទេសកម្ពុជា។ គោលនយោបាយនេះរួមមាន និយមន័យនៃការរំលោភបំពាន ក្រមសីលធម៌ការពារសុវត្ថិភាពកុមារ សម្រាប់មនុស្សទាំងអស់ដែលមានអាយុលើស១៨ឆ្នាំកំពុងរស់នៅក្នុងវត្តអារាម រួមទាំងព្រះសង្ឃ អាចារ្យ គណៈកម្មការ តាជី ដូនជី ក្មេងវត្ត អ្នកស្នាក់នៅបណ្តោះអាសន្ន និងអ្នកស្ម័គ្រចិត្ត និងក្របខ័ណ្ឌការងារ រាយការណ៍ ដើម្បីជាមគ្គុទេសក៍ចង្អុលបង្ហាញការរាយការណ៍ និងសកម្មភាពបញ្ជូនដែលចាំបាច់ត្រូវធ្វើ ឡើងឆ្លើយតបក្នុងករណីសង្ស័យ ឬករណីត្រូវបានរាយការណ៍អំពីអំពើហិង្សា និងការរំលោភបំពានលើ កុមារក្នុងទីវត្តអារាម។

## ជនបង្គោលការពារសុវត្ថិភាពកុមារ និងការទទួលខុសត្រូវក្នុងការរាយការណ៍

ជនបង្គោលការពារសុវត្ថិភាពកុមារ នឹងត្រូវបង្កើតឡើងនៅតាមកម្រិតនីមួយៗ រួមទាំងថ្នាក់វត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ។ ជនបង្គោលនីមួយៗមានការទទួលខុសត្រូវ ជាក់លាក់ក្នុងការអនុវត្ត និងពិនិត្យ តាមដានលើកម្មវិធីការពារកុមារតាមវត្តអារាម ដោយមានការគាំទ្រ ពីថៅអធិការ មន្ត្រីសង្ឃ មន្ត្រីក្រសួងធម្មការ និងសាសនា និងក្រុមគ្រូបណ្តុះបណ្តាលថ្នាក់ជាតិ។ ជនបង្គោលនៅក្នុងវត្តមានតួនាទីដោយផ្ទាល់ក្នុងការរាយការណ៍ និងឆ្លើយតបចំពោះករណីសង្ស័យ អំពើហិង្សា និងការរំលោភបំពានលើកុមារ ក្នុងការលើកកម្ពស់ការយល់ដឹងនៅក្នុងវត្តនិងនៅក្នុង សហគមន៍ ជនបង្គោលថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិទទួលខុសត្រូវក្នុង ការផ្តល់ប្រឹក្សា ស្តីពីសកម្មភាពដែលត្រូវធ្វើឡើងពេលមានការស្នើសុំយោបល់ ត្រូវធ្វើសកម្មភាពនៅ ថ្នាក់លើតាមការសមស្រប និងក្នុងការពិនិត្យតាមដាន និងរាយការណ៍។ ជនបង្គោលទាំងអស់ត្រូវបាន រំពឹងថានឹងចូលរួមក្នុងការលើកកម្ពស់ការយល់ដឹងនិងចំណេះដឹងអំពីការរំលោភបំពានលើកុមារ និង អំពើហិង្សាលើកុមារ និងនៅក្នុងបរិបទនៃគោលការណ៍ និងការបង្រៀនរបស់ពុទ្ធសាសនា។

### ៣.១.២. ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងដើម្បីបង្ការ និងឆ្លើយតប ចំពោះអំពើហិង្សាលើកុមារ

- ការបណ្តុះបណ្តាលកសាងសមត្ថភាពសម្រាប់ព្រះសង្ឃ
- ការលើកកម្ពស់ការយល់ដឹងក្នុងវត្តអារាមតាមរយៈការអប់រំ និងសកម្មភាពដទៃទៀត
- ការលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍តាមរយៈការអប់រំ ការផ្សព្វផ្សាយតាម មូលដ្ឋាន សកម្មភាពដទៃទៀត និងការគាំទ្រចំពោះកុមារ និងគ្រួសារប្រឈមហានិភ័យ

## ក្រុមបណ្តុះបណ្តាលថ្នាក់ជាតិ

ក្រុមបណ្តុះបណ្តាលថ្នាក់ជាតិមួយនឹងត្រូវបានបង្កើតឡើងដោយគណៈសង្ឃ និងសម្របសម្រួលពីក្រសួងធម្មការ និងសាសនា។ ការបណ្តុះបណ្តាលគ្រូបង្គោលនឹងត្រូវធ្វើឡើង សម្រាប់សមាជិកក្រុមបណ្តុះបណ្តាល ដោយមានកម្មវិធីសិក្សាត្រូវបានបង្កើតឡើង និងបានទទួលគ្រូបណ្តុះបណ្តាលក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការយូនីសេហ្វកម្ពុជា។ កម្មវិធីសិក្សាដែលឆ្លើយតបលើការបង្ការ និងការឆ្លើយតបអំពើហិង្សាលើកុមារក្នុងបរិបទសិទ្ធិកុមារ ច្បាប់អន្តរជាតិ និងច្បាប់ជាតិ និងសីលធម៌ វិន័យព្រះពុទ្ធសាសនាក៏នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំពុទ្ធិកៈទាំងបីកម្រិត(ថ្នាក់បឋម ថ្នាក់មធ្យម និងថ្នាក់ឧត្តម)។

ផែនការមួយនឹងត្រូវបានបង្កើតឡើងរួមជាមួយគណៈសង្ឃនាយក ក្រសួងធម្មការ និងសាសនា និងលេខាធិការដ្ឋានគណៈសង្ឃនាយក សម្រាប់ការចាប់អនុវត្តការបណ្តុះបណ្តាលនេះ ទៅដល់ជនបង្គោលការពារសុវត្ថិភាពកុមារនៅតាមវត្តអារាម ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត ។ យើងទទួលស្គាល់ថាក្រុមបណ្តុះបណ្តាលចាំបាច់ត្រូវបានទទួលពេលវេលាគ្រប់គ្រាន់ ដើម្បីអនុវត្តការបណ្តុះបណ្តាលដែលចាំបាច់។ របាយការណ៍ស្តីពីការបណ្តុះបណ្តាលនឹងត្រូវផ្តល់ជូនដល់ជនបង្គោលនៅថ្នាកការិយាល័យធម្មការ និងសាសនា ថ្នាក់មន្ទីរធម្មការ និងសាសនា ព្រមទាំងថ្នាក់ជាតិ។ ការបណ្តុះបណ្តាលរម្លឹកឡើងវិញចាំបាច់ត្រូវធ្វើឡើងជាទៀងរាល់ឆ្នាំ។

## ការលើកកម្ពស់ការយល់ដឹងនៅក្នុងវត្តអារាម

ជនបង្គោលការពារសុវត្ថិភាពកុមារ ក្នុងកិច្ចសហការជាមួយចៅអធិការនឹងធានាយ៉ាងណាឱ្យជនទាំងឡាយដែលស្នាក់នៅ ឬមានទំនាក់ទំនងជាមួយវត្តអារាមត្រូវយល់ច្បាស់អំពីអ្វីខ្លះ ដែលធ្វើឱ្យកើតមានការរំលោភបំពានលើកុមារ និងអំពើហិង្សាលើកុមារនឹងឱ្យពួកគេដឹងច្បាស់ថាទង្វើទាំងអស់នេះត្រូវបានហាមឃាត់នៅក្នុងបរិវេណវត្តអារាម។ ជនបង្គោល និងចៅអធិការក៏ត្រូវប្រាប់អ្នកទាំងនោះឱ្យដឹងអំពីគោលនយោបាយការពារសុវត្ថិភាពកុមារ ហើយត្រូវធានាឱ្យបានថាអ្នកស្នាក់នៅជាមនុស្សពេញវ័យទាំងអស់ (រួមទាំងព្រះសង្ឃ ដូនជី ភិក្ខុ សាមណេរ និងអ្នកស្ថិតក្រោមការថែទាំ) និងមនុស្សពេញវ័យពុំមែនជាអ្នកស្នាក់នៅក្នុងវត្ត (រួមទាំងអ្នកស្ម័គ្រចិត្ត និងសមាជិកសហគមន៍) ត្រូវយល់ និងចុះហត្ថលេខាលើក្រមសីលធម៌។ ចៅអធិការវត្ត ព្រះសង្ឃ និងគ្រហស្ថ (ឧ. អាចារ្យ និងដូនជី) ក៏ត្រូវចូលរួមចំណែកក្នុងការលើកកម្ពស់ការយល់ដឹងនិងចំណេះដឹងអំពីអំពើហិង្សាលើកុមារ ព្រមទាំងផលវិបាករបស់អំពើហិង្សាមកលើការអភិវឌ្ឍរបស់កុមារនៅក្នុងបរិបទ នៃសកម្មភាពជាប្រចាំរបស់ពួកគេ ដូចជាម៉ោងបង្រៀនភាសាអង់គ្លេសសម្រាប់កុមារកម្មវិធីសមាធិ និងពិធីបុណ្យសាសនានៅតាមវត្តជាដើម។

## ការលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍

ការលើកកម្ពស់ការយល់ដឹង និងការបញ្ជ្រាបចំណេះដឹងដល់សហគមន៍គឺជាតួនាទីដ៏សំខាន់របស់ព្រះសង្ឃនៅថ្នាក់សហគមន៍។ ព្រះសង្ឃ និងអ្នកដឹកនាំសាសនាអាចលើកទឹកចិត្តសហគមន៍ឱ្យឆ្លុះបញ្ចាំងលើបញ្ហាអំពើហិង្សាលើកុមារ និងប្រយោជន៍នៃការគាំទ្រឱ្យកុមាររស់នៅក្នុងគ្រួសារតាមរយៈធម្មទេសនា ការបួងសួង និងមគ្គុទេសក៍ផ្នែកស្មារតីដោយប្រើប្រាស់ធម៌វិន័យ និងរឿងប្រៀបធៀបដែលមានក្នុងព្រះពុទ្ធសាសនា។ វិធីមួយចំនួនដែលអាចយកទៅប្រើដើម្បីលើកកម្ពស់ការយល់ដឹងមានដូចជាៈ

- ការឆ្លើយតបបញ្ហាអំពើហិង្សាលើកុមារ និងការអប់រំសហគមន៍អំពីទម្រង់នានានៃអំពើហិង្សា ព្រមទាំងផលវិបាកនៃអំពើហិង្សាចំពោះកុមារ និងសង្គមនៅពេលព្រះសង្ឃចូលរួមជាអធិបតីនៅក្នុងពិធីបុណ្យសាសនា និងកម្មវិធីផ្សេងៗ។
- កៀងគរសហគមន៍ឱ្យបង្កើតបរិស្ថានប្រកបដោយការការពារសម្រាប់កុមារ និងអត្ថប្រយោជន៍នៃការគាំទ្រកុមារឱ្យរស់នៅជាមួយគ្រួសារ។
- ចុះសួរសុខទុក្ខគ្រួសារពេលមានវិបត្តិ ការផ្តល់ប្រឹក្សា ការចង្អុលបង្ហាញផ្នែកសីលធម៌ និងការផ្សារភ្ជាប់ជាមួយសេវាសង្គមដែលចាំបាច់នានា។
- សម្របសម្រួលជាមួយ គ.ក.ន.ក. ឱ្យធ្វើផែនទីហានិភ័យចំពោះកុមារនៅក្នុងសហគមន៍ ដើម្បីធ្វើផែនការកម្មវិធីសហគមន៍ជាកិច្ចឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងអត្ថប្រយោជន៍នៃការគាំទ្រកុមារឱ្យរស់នៅជាមួយគ្រួសារ និងនៅក្នុងយុទ្ធនាការផ្សេងៗ ឧ. ដូចជាការចុះសំបុត្រកំណើត សិទ្ធិស្មើគ្នាសម្រាប់កុមារពិការ និងបញ្ហាដទៃទៀតពាក់ព័ន្ធជាមួយការការពារកុមារ និងស្ថាបនាចំណងទាក់ទងជាមួយវត្តដទៃទៀត ស្ថាប័នសាសនាដទៃទៀត ឬ NGO នានា។

គ្រប់ពេលដែលអាចធ្វើបាន ព្រះសង្ឃនិងវត្តអារាម គួរសម្របសម្រួលការផ្តល់សារជាមួយអ្នកដើរតួនាទីដទៃទៀត រួមទាំងជាមួយក្រុមប្រឹក្សាឃុំ មន្ទីររដ្ឋាភិបាលនៅថ្នាក់ស្រុក សាលារៀន មណ្ឌលសុខភាព និងសង្គមស៊ីវិល។ តាមរយៈការសម្របសម្រួលលើប្រធានបទ និងការកំណត់ពេលវេលាទាំងនេះ ធ្វើឱ្យផលប៉ះពាល់នៃការផ្តល់សារអាចកើនឡើងទ្វេដងថែមទៀត។ ក្រសួងធម្មការ និងសាសនា ដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រាស្រ័យទាក់ទងជាមួយក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ស្តីពី អត្តិភាពថ្នាក់ជាតិ និងយុទ្ធនាការនិងក្នុងការបញ្ជូនព័ត៌មាននេះទៅដល់វត្តអារាមនៅថ្នាក់ឃុំ។ នៅក្នុងតួនាទីនេះ ក្រសួងអាចដាក់បញ្ចូលសារនានាទាក់ទងជាមួយការកែលម្អសុវត្ថិភាពកុមារ ឱ្យរួចផុតពីអំពើហិង្សា និងការរំលោភបំពាន។

### ៣.១.៣. ការពិនិត្យតាមដាន និងការវាយតម្លៃ

- ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្ត
- ការរាយការណ៍លទ្ធផលកម្មវិធី
- ការផ្តល់ពានរង្វាន់ និងវិញ្ញាបនបត្របញ្ជាក់វត្តសង្គហកុមារ

### ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្ត

ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តកម្មវិធី គឺជាការទទួលខុសត្រូវរបស់អ្នកដើរតួនាទី ជាច្រើន ជាពិសេសគឺមន្ត្រីធម្មការ និងសាសនានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ។ នាយកដ្ឋានកិច្ចការពុទ្ធសាសនារបស់ក្រសួងធម្មការ និងសាសនា ជួយចង្អុលបង្ហាញ ព្រមទាំងគាំទ្រដំណើរការនៃការប្រមូលរបាយការណ៍ការពិនិត្យតាមដាន និងវាយតម្លៃ។ បុគ្គលិកអង្គការយូនីសេហ្វនឹងទទួលខុសត្រូវក្នុងការសម្របសម្រួលទស្សនកិច្ចពិនិត្យតាមដាន ជាមួយមន្ត្រីក្រសួងធម្មការនិងសាសនា និងលេខាធិការដ្ឋានសង្ឃនាយក។ ពួកគេនឹងពិនិត្យតាមដានលើទិដ្ឋភាពទាំងអស់នៃការអនុវត្តកម្មវិធី ដើរតួនាទីផ្នែកប្រាស្រ័យទាក់ទងរវាងក្រសួងធម្មការ និងសាសនា និងអង្គការយូនីសេហ្វហើយក៏នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋានសង្ឃនាយកផងដែរ។

បញ្ហាសំខាន់ៗ ដែលត្រូវពិនិត្យតាមដាន និងវាយតម្លៃរួមមាន៖

- គុណភាពនៃការបណ្តុះបណ្តាលអនុវត្តដោយក្រុមបណ្តុះបណ្តាលថ្នាក់ជាតិ និងដោយអ្នកដើរតួនាទីថ្នាក់ ក្រុង ស្រុក ខណ្ឌ។
- វឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយរក្សាសុវត្ថិភាពកុមារតាមវត្តអារាម រួមទាំងសមាសធាតុទាំងអស់ (ឧ. ការតែងតាំងជនបង្គោលការពារសុវត្ថិភាពកុមារ ការលើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយ ទាំងសម្រាប់មនុស្សពេញវ័យ និងកុមារ ការចុះហត្ថលេខាលើក្រមសីលធម៌ដោយមនុស្សពេញវ័យ ការយល់ដឹងជាមូលដ្ឋានអំពីប្រភេទនៃអំពើហិង្សានិងការរំលោភបំពានលើកុមារ និងរបៀបដើម្បីរាយការណ៍)។
- ការអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ និងការចូលរួមរបស់ គ.ក.ន.ក.
- ការរក្សាកំណត់ត្រាអំពីកុមារកំពុងស្នាក់នៅក្នុងវត្តអារាម និងកុមារដែលប្រឈមហានិភ័យក្នុងសហគមន៍។

## ការរាយការណ៍លទ្ធផលកម្មវិធី

ក្រសួងធម្មការ និងសាសនាជាអ្នកទទួលខុសត្រូវចម្បងក្នុងការរាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីការពារកុមារតាមវត្តអារាមជូនដល់រដ្ឋាភិបាល ដោយចម្លងជូនថ្វាយប្រគេន គណៈសង្ឃនាយក និង អង្គការយូនីសេហ្វ។ ការងារនេះរួមមានការប្រមូលចងក្រងរបាយការណ៍ដែលបានទទួលពីវត្តដែលចូលរួម និងពីប្រធានការិយាល័យធម្មការនិងសាសនា ប្រធានមន្ទីរធម្មការ និងសាសនា ព្រះអនុគណ និងព្រះមេគណ។ វត្តនីមួយៗមានភារកិច្ចបញ្ជូនរបាយការណ៍លទ្ធផល និងសកម្មភាព (ឧបសម្ព័ន្ធ ៨) ទៅព្រះអនុគណប្រចាំត្រីមាស ដោយថតចម្លងជូនការិយាល័យធម្មការ និងសាសនា ដើម្បីចងក្រងរបាយការណ៍សរុបប្រគេនព្រះមេគណ និងប្រធានមន្ទីរធម្មការ និងសាសនា។ របាយការណ៍វឌ្ឍភាពនិងលទ្ធផលប្រចាំត្រីមាស និងប្រចាំឆ្នាំ និងការចំណាយថវិកានឹងត្រូវផ្តល់ជូនដល់អង្គការយូនីសេហ្វផងដែរ។

**យន្តការប្រមូលរបាយការណ៍លទ្ធផលកម្មវិធីវត្តសង្គហកុមារ**




## សូចនាករលទ្ធផលកម្មវិធី៖

- ចំនួនព្រះសង្ឃបានទទួលការបណ្តុះបណ្តាលអំពីការការពារកុមារ
- ចំនួនវត្តដែលអនុវត្តការដាក់ពិន័យជាវិជ្ជមាន និងការអនុវត្តការចិញ្ចឹមបីបាច់កុមារដោយវិជ្ជមាន
- ចំនួនវត្តដែលមានហត្ថលេខារបស់មនុស្សពេញវ័យទាំងអស់នៅលើក្រមសីលធម៌
- ចំនួនវត្តដែលភាគច្រើននៃអ្នករស់នៅ និងបុគ្គលមានទំនាក់ទំនងជាមួយវត្តបានដឹង អំពីគោលការណ៍ការពារសុវត្ថិភាពកុមារតាមវត្តអារាម និងអំពីរបៀបរាយការណ៍ករណីសង្ស័យការរំលោភ បំពាន រួមទាំងសាមណេរ ក្មេងៗផងដែរ

- ចំនួនវត្តដែលមានប្រព័ន្ធរាយការណ៍ និងបញ្ជូនបំពេញមុខងារត្រឹមត្រូវស្តីពីការការពារកុមារដែលត្រូវបានបង្ហាញដោយចំនួនករណីរាយការណ៍
- ចំនួនសកម្មភាពដែលត្រូវបានធ្វើឡើងដោយព្រះសង្ឃ និងគ្រហស្ថ (អាចារ្យ និងដូនជី) ក្នុងសហគមន៍ដើម្បីលើកកម្ពស់ការបង្ការអំពើហិង្សា និងដើម្បីគាំទ្រឱ្យកុមាររស់នៅជាមួយគ្រួសារ
- ចំនួនព្រះសង្ឃដែលត្រូវបានទទួលស្គាល់ជាជនគំរូ និងចំនួនវត្តដែលបានទទួលវិញ្ញាបនបត្របញ្ជាក់វត្តសង្គហកុមារ។

## វិញ្ញាបនបត្រ និងរង្វាន់មេដាយវត្តសង្គហកុមារ

ដើម្បីលើកទឹកចិត្តការអនុវត្ត និងដើម្បីទទួលស្គាល់កិច្ចខិតខំ និងវឌ្ឍនភាពដែលបានធ្វើឡើងដើម្បីឱ្យវត្តអារាមកាន់តែមានសុវត្ថិភាពចំពោះកុមារ វិញ្ញាបនបត្រ និងរង្វាន់មេដាយវត្តសង្គហកុមារនឹងត្រូវបានបង្កើតឡើង។ វិញ្ញាបនបត្រ និងមេដាយនឹងត្រូវប្រគល់ចំពោះព្រះសង្ឃទាំងឡាយណាដែលបានបង្ហាញឱ្យឃើញថាខ្លួនជាជនគំរូ និងជាវត្តគំរូដែលបង្ហាញការប្តេជ្ញាចិត្ត និងសកម្មភាពជាក់ស្តែងរបស់ខ្លួនដើម្បីកែលម្អកិច្ចការពារកុមារនៅក្នុងវត្តរបស់ខ្លួន និងដើម្បីកៀងគរសហគមន៍ជើងវត្ត ដើម្បីបង្កើតបរិស្ថានប្រកបដោយការការពារសម្រាប់កុមារ។

គណៈកម្មាធិការផ្តល់វិញ្ញាបនបត្រវត្តសង្គហកុមារផ្លូវការនៅថ្នាក់ជាតិ និងថ្នាក់ខេត្តនឹងត្រូវបានបង្កើតឡើងដោយក្រសួងធម្មការ និងសាសនា ហើយសម្តេចព្រះសង្ឃរាជមានភារកិច្ចពិនិត្យតាមដានវាយតម្លៃ និងអនុម័តលើការផ្តល់វិញ្ញាបនបត្រ និងមេដាយនេះ។ ដើម្បីគាំទ្រដំណើរការនេះ បញ្ជីផ្ទៀងផ្ទាត់ជាក់លាក់នឹងត្រូវបានបង្កើតឡើង និងចែករំលែកជាមួយវត្តដែលចូលរួមនីមួយៗ (ឧបសម្ព័ន្ធ គ)។ ការផ្តល់ជូនដល់វត្តនឹងមានសុពលភាពរយៈពេលពីរឆ្នាំ ចំណែកការផ្តល់ជូនចំពោះព្រះសង្ឃជាជនគំរូនឹងមានសុពលភាពពេញមួយជីវិត។ រង្វាន់ទាំងពីរនេះគឺជាកម្មវត្ថុនៃការវាយតម្លៃឡើងវិញដោយគណៈកម្មាធិការផ្តល់វិញ្ញាបនបត្រ ហើយអាចត្រូវបានដកយកវិញ ប្រសិនបើវត្តមិនបានរក្សាបទដ្ឋានកំណត់ ឬមានភស្តុតាងបង្ហាញថាអ្នកទទួលរង្វាន់នោះបានប្រព្រឹត្តអំពើហិង្សា ឬបទល្មើសណាមួយប្រឆាំងច្បាប់រដ្ឋ ឬច្បាប់ពុទ្ធសាសនា។

### ៣.១.៤. កត្តាសំខាន់ៗចំពោះជោគជ័យរបស់កម្មវិធី

ជោគជ័យ និងនិរន្តរភាពរបស់កម្មវិធីពឹងផ្អែកលើកត្តាសំខាន់ៗមួយចំនួនដូចជា៖

- ការគាំទ្រជាផ្លូវការពីសម្តេចព្រះសង្ឃនាយក និងមន្ត្រីសង្ឃ ដោយមានការគាំទ្រ និងកិច្ចសហប្រតិបត្តិការរបស់ក្រសួងធម្មការនិងសាសនា ចំពោះកម្មវិធីនេះ។

- ការចេញគោលការណ៍ដោយគណៈសង្ឃនាយក ទៅដល់មន្ត្រីសង្ឃរាជធានី ខេត្ត និងមន្ត្រីសង្ឃក្រុង ស្រុក ខណ្ឌ ដើម្បីជានាន្ទវការអនុវត្តនៅគ្រប់កម្រិតទាំងអស់ រួមទាំងតាមវត្តអារាមផងដែរ។
- ការបង្កើតការិយាល័យ ឬយន្តការដោយក្រសួងធម្មការនិងសាសនា ដើម្បីពិនិត្យតាមដានសុខុមាលភាពកុមារកំពុងរស់នៅក្នុងវត្តអារាម និងដើម្បីរក្សាកំណត់ត្រាបច្ចុប្បន្នភាពអនុលោមតាមតម្រូវការរបស់ប្រកាសស្តីពីការថែទាំជំនួសសម្រាប់កុមារនៅក្នុងសហគមន៍។

## ៤. ផែនការអនុវត្ត

វត្តសង្គហកុមារ (កម្មវិធីការពារកុមារតាមវត្តអារាម) ត្រូវបានតាក់តែងឡើងជាដំបូង ដើម្បីអនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរយៈពេលបីឆ្នាំចាប់ពីឆ្នាំ២០១៨ ក្នុងខេត្តគោលដៅចំនួនប្រាំគឺខេត្ត បាត់ដំបង ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប និងផ្តោតគោលដៅលើវត្តចំនួន៣០០វត្ត។ ចំនួនព្រះសង្ឃនៅក្នុងវត្តទាំង៣០០នេះ មានប្រមាណ៣.០០០អង្គ ដែលនឹងបានទទួលការបណ្តុះបណ្តាលស្តីពីកម្មវិធីការពារកុមារតាមវត្តអារាម។ កម្មវិធីរំពឹងថាកុមារប្រមាណ១០.០០០នាក់ដែលកំពុង រស់នៅក្នុងវត្តនិងនៅក្បែរវត្តនឹងបានទទួលអត្ថប្រយោជន៍តាម រយៈសកម្មភាពការអប់រំតាមមូលដ្ឋាន។ កម្មវិធីកិច្ចការពារកុមារតាមវត្តអារាម និងបន្តអនុវត្តនៅតាមវត្តទូទាំងប្រទេសបន្ទាប់ពីការវាយតម្លៃលទ្ធផលអនុវត្តរយៈពេល៣ឆ្នាំរួច។

ក្នុងរយៈពេលឆ្នាំទីមួយនៃការអនុវត្ត ក្រសួងធម្មការនិងសាសនា និងគណៈសង្ឃនាយក វត្តចំនួន៥ នឹងត្រូវបានជ្រើសរើសក្នុងខេត្តនីមួយៗ ជាហេតុធ្វើឱ្យមានវត្តសរុបចំនួន២៥វត្ត នៅក្នុងការអនុវត្តដំណាក់កាលដំបូង។ ក្នុងវត្តទាំង២៥នេះ ព្រះសង្ឃ ឬជនបង្គោលប្រចាំវត្តចំនួន៧៥អង្គ/នាក់ត្រូវបានរំពឹងថានឹងបានទទួលអត្ថប្រយោជន៍ពីការបណ្តុះបណ្តាល ដើម្បីបង្ការនិងឆ្លើយតបចំពោះអំពើហិង្សាលើ កុមារានិងកុមារីក្នុងវត្តនិងសហគមន៍ជើងវត្ត។ ការបណ្តុះបណ្តាលក៏នឹងឆ្លើយតបផងដែរចំពោះប្រយោជន៍ ក្នុងការគាំទ្រកុមារឱ្យរស់នៅជាមួយគ្រួសារផងដែរ។

ដំណាក់កាលដំបូង នៃកម្មវិធីវត្តសង្គហកុមារ នឹងរួមបញ្ចូលនូវការសរសេរបញ្ចប់កម្មវិធីបណ្តុះបណ្តាលជាស្ពាពរការបណ្តុះបណ្តាលគ្រូបង្គោល និងការបណ្តុះបណ្តាលព្រះសង្ឃនៅក្នុងខេត្តមួយដែល សកម្មភាព នឹងត្រូវបានយកទៅអនុវត្តសាកល្បងពិនិត្យឡើងវិញ និងកែសម្រួលតាមការចាំបាច់។ ការអនុវត្តវត្តសង្គហកុមារ (គោលនយោបាយការពារកុមារតាមវត្តអារាម) ក៏នឹងត្រូវបានយកទៅអនុវត្តសាកល្បងក្នុងខេត្តនេះផងដែរ ដោយមានសិក្ខាសាលាដែលរៀបចំឡើងសម្រាប់ព្រះសង្ឃដែលចូលរួមដើម្បី ចែករំលែកបទពិសោធន៍របស់ខ្លួន។ បន្ទាប់មកផែនការចាប់ផ្តើមអនុវត្តនឹងត្រូវបានបង្កើតឡើងដោយក្រសួងធម្មការ និងសាសនា ក្នុងកិច្ចសហប្រតិបត្តិការជាមួយព្រះមេគណ ព្រមទាំង

ប្រធានមន្ទីរធម្មការនិងសាសនា និងជាមួយអង្គការយូនីសេហ្វ។ ដំណាក់កាលនេះក៏រួមមានការបង្កើត ការផលិតឡើងវិញ និងការចែកចាយសម្ភារៈ បន្ទាប់ពីការកែសម្រួលបានទទួលពីការរកឃើញនៃការអនុវត្តសាកល្បងផ្ទាល់នៅមូលដ្ឋាន។

ដំណាក់កាលបន្តបន្ទាប់ទៀត នឹងត្រូវផ្តោតការយកចិត្តទុកដាក់លើតួនាទីកាន់តែច្រើនឡើងនៃកម្មវិធីផ្អែកលើកាលវិភាគបណ្តុះបណ្តាលដែលបានអនុម័ត និងផែនការអនុវត្តការងារ។ យើងរំពឹងថាការពង្រីកកម្មវិធីនឹងមានដាក់បញ្ចូលមេរៀនជាបទពិសោធន៍ ហើយនឹងត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈការចែករំលែកបទពិសោធន៍ពីបណ្តាវត្ត និងព្រះសង្ឃចូលរួមក្នុងការអនុវត្តសាកល្បង ដែលបានក្លាយជាជនគំរូសម្រាប់ការការពារកុមារ។ ក្នុងរយៈពេលនេះ ព័ត៌មានដំបូងនឹងត្រូវបានប្រមូលតាមវត្តនានានៅក្នុងសហគមន៍ និងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់ការវាយតម្លៃកម្មវិធី ហើយការចុះពិនិត្យតាមដាន រួមគ្នាដោយក្រសួងធម្មការនិងសាសនា ជាមួយយូនីសេហ្វនឹងត្រូវធ្វើឡើង ដើម្បីវាយតម្លៃវឌ្ឍនភាព។ (ឧបសម្ព័ន្ធ ខ)

## ៥. ថវិកា

ក្នុងរយៈពេល៣ឆ្នាំដំបូងនៃការអនុវត្ត ការគាំទ្រថវិកាក្នុងសកម្មភាពវត្តសង្គហកុមារ ស្ថិតក្រោមគម្រោងជាក់ស្តែងនៃអង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍន៍ រួមទាំងសប្បុរសជននានាដោយមានទាំងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលផងដែរ។ បន្ទាប់ពីគម្រោងរយៈពេល៣ឆ្នាំ ក្រសួងធម្មការនិងសាសនានឹងស្នើសុំថវិកាពីរាជរដ្ឋាភិបាលដើម្បីបន្តអនុវត្តកម្មវិធីនៅទូទាំងប្រទេស ដោយសហការជាមួយគណៈសង្ឃនាយក។

| វិស័យ/សកម្មភាពផ្តោតការយកចិត្តទុកដាក់ | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | សរុប |
|---|---|---|---|---|
| ១. គោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម | | | | |
| ការគាំទ្រផ្នែកបច្ចេកទេសក្នុងការបង្កើតគោលនយោបាយ និងគាំទ្រលើសម្ភារៈ | | | | |
| គោលនយោបាយការពារសុវត្ថិភាពកុមារសម្រាប់វត្តអារាមត្រូវបានអនុម័ត និងអនុវត្តនៅក្នុងវត្តទាំង ៣០០ ក្នុងប្រទេស | | | | |
| សកម្មភាពលើកកម្ពស់ការយល់ដឹងនៅក្នុងវត្ត | | | | |
| សកម្មភាពលើកកម្ពស់ការយល់ដឹង និងកម្មវិធីនានានៅក្នុងសហគមន៍ | | | | |
| ២. ពង្រឹងសមត្ថភាពព្រះសង្ឃដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | | | | |

| | | | | |
|---|---|---|---|---|
| កម្មវិធី និងសម្ភារៈបណ្តុះបណ្តាលត្រូវបានបង្កើតឡើង និង យកទៅអនុវត្តនៅមូលដ្ឋានជាក់ស្តែងក្នុងខេត្តចំនួនមួយ និង ជាមួយព្រះសង្ឃឈានមុខ | | | | |
| ក្រុមបណ្តុះបណ្តាលថ្នាក់ជាតិត្រូវបានបង្កើតឡើង បានទទួល TOT ហើយផែនការការបណ្តុះបណ្តាលត្រូវបានអនុវត្ត | | | | |
| សិក្ខាសាលារម្លឹកឡើងវិញ និងការផ្លាស់ប្តូរបទពិសោធន៍ | | | | |
| ៣. ការពិនិត្យតាមដាន និងរាយការណ៍ | | | | |
| ទស្សនកិច្ចចុះពិនិត្យតាមដាន | | | | |
| ការវាយតម្លៃវឌ្ឍនភាព (រួមទាំងសិក្ខាសាលាប្រចាំឆ្នាំ) | | | | |
| សម្ភារៈ IEC សម្រាប់វិញ្ញាបនបត្រ និងរង្វាន់ | | | | |
| **៤. ការគ្រប់គ្រងកម្មវិធី** | | | | |
| សម្ភារៈផ្គត់ផ្គង់ការិយាល័យ ឧបករណ៍ការិយាល័យ និង □□ | | | | |
| ការបង្កើតមូលដ្ឋានទិន្នន័យចំនួនព្រះសង្ឃ និងគ្រហស្ថក្នុងវត្ត | | | | |
| ថ្លៃសេវាអ្នកពិគ្រោះយោបល់/ប្រាក់ឧបត្ថម្ភកម្មសិក្សាការី | | | | |
| **សរុប** | | | | |

## ៦. ឧបសម្ព័ន្ធ
## ឧបសម្ព័ន្ធ ១៖ ក្រមសីលធម៌កិច្ចការពារកុមារតាមវត្តអារាម

ឈ្មោះវត្ត៖ ......................ឃុំ/សង្កាត់…………ខណ្ឌ/ស្រុក……………រាជធានី/ខេត្ត…………………

ក្រមសីលធម៌ខាងក្រោមនេះ ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃកម្មវិធីវត្តសង្គហកុមារ “កិច្ចការពារកុមារតាមវត្តអារាម” ក្រោមការចង្អុលបង្ហាញរបស់ក្រសួងធម្មការ និងសាសនា និងព្រះមហាសង្ឃរាជ និងអនុលោមតាមព្រះធម៌វិន័យព្រះពុទ្ធសាសនា។ ក្រមសីលធម៌នេះ ឆ្លុះបញ្ចាំងអំពីគោលការណ៍របស់ពុទ្ធសាសនាដែលមានចែងក្នុងព្រះត្រៃបិដក។ ក្រមសីលធម៌នេះ គឺជាកិច្ចខិតខំដើម្បីលើកកម្ពស់ក្រមសីលធម៌បុគ្គល និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់បំផុតចំពោះកុមារសម្រាប់គ្រប់សកម្មភាពទាំងអស់របស់មនុស្សពេញវ័យ (មនុស្សអាយុ១៨ ឆ្នាំឡើងទៅ) ដែលពាក់ព័ន្ធជាមួយវត្តអារាមក្នុងនាមជាអ្នកស្នាក់នៅ ឬអ្នកចូលមកមានទំនាក់ទំនងជាមួយវត្ត ដូចជាអ្នកស្ម័គ្រចិត្ត នឹងត្រូវអនុវត្តផងដែរទាំងនៅក្នុងវត្តអារាម និងបរិយាកាសក្រៅវត្តអារាម។

អាត្មាភាព ខ្ញុំបាទ នាងខ្ញុំ យល់ព្រមចំពោះចំណុចដូចខាងក្រោម៖

១. **គោរពសេចក្តីថ្លៃថ្នូរផ្នែករាងកាយរបស់កុមារទាំងអស់** និងមិនរំលោភបំពាន ឬប្រព្រឹត្តអំពើហិង្សាលើកុមារឡើយ (រួមទាំងក្នុងបំណងដើម្បីដាក់ពិន័យផងដែរ)។

២. **គោរពសេចក្តីថ្លៃថ្នូរផ្នែកផ្លូវចិត្តរបស់កុមារទាំងអស់** និងមិនធ្វើសកម្មភាពតាមវិធីណាមួយ ដែលធ្វើឱ្យអាម៉ាស់ បន្តុះបង្អាប់ មើលស្រាល បន្ទាបបន្ថោក រើសអើង ឬបង្ហាញការប្រព្រឹត្តមិនដូចគ្នាចំពោះកុមារ (រួមទាំងដោយសារមូលហេតុជាតិសាសន៍ ពណ៌សម្បុរ យេនឌ័រ ពិការភាពឬស្ថានភាពកំណើតផងដែរ)។

៣. **មិនចូលរួមក្នុងសកម្មភាពផ្លូវភេទ ឬអាកប្បកិរិយាពាក់ព័ន្ធផ្លូវភេទជាមួយកុមារ** រួមទាំងកុមារដែលត្រូវបានគេកេងប្រវ័ញ្ចន៍តាមរយៈពេស្យាចារ ដោយមិនគិតពីអាយុនៃការព្រមព្រៀង និង

តមមិនមើល មិនមានទុកជាជាកម្មសិទ្ធិ ផលិត ឬចែកចាយ រូបភាពឬសម្ភារៈអាសអាភាសរបស់កុមារ។

៤. **មិនឱ្យកុមារអាយុក្រោម១៨ឆ្នាំ ចូលរួមពាក់ព័ន្ធក្នុងការងារ ដែលអាចបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍរបស់ពួកគេ** រួមទាំងការងារដែលមានគ្រោះថ្នាក់ចំពោះសុខភាពរំខានដល់ការអប់រំនិងការអភិវឌ្ឍផ្នែកខួរក្បាលរបស់ពួកគេ ហើយដែលអាចជះឥទ្ធិពលដល់ការអភិវឌ្ឍផ្នែកស្មារតីសីលធម៌ និង/ឬសង្គមរបស់ពួកគេ (រួមទាំងការងារផ្ទះ)។

៥. **មិនត្រូវជាប់ពាក់ព័ន្ធក្នុងការកេងប្រវ័ញ្ចន៍កុមារ** ទោះជាដោយផ្ទាល់ ឬដោយប្រយោល ឬដាក់កុមារក្នុងស្ថានភាពដែលអាចធ្វើឱ្យពួកគេមានភាពងាយរងគ្រោះ ចំពោះទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ និងអំពើហិង្សា។

៦. **រាយការណ៍ជាបន្ទាន់ជូនដល់អ្នកទទួលបន្ទុកការពារសុវត្ថិភាពកុមារ ឬព្រះចៅអធិការចំពោះករណី សង្ស័យអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចន៍កុមារ** និងរាល់ទង្វើទាំងឡាយណាដែលជាការរំលោភបំពានលើក្រមសីលធម៌ការពារកុមារនេះ។

អាត្មាភាព ខ្ញុំបាទ នាងខ្ញុំ ទទួលស្គាល់ថា បានយល់ និងយល់ស្របចំពោះក្រមសីលធម៌ការពារសុវត្ថិភាពកុមារនេះ ហើយសូមប្រកាសថា អាត្មាភាព ខ្ញុំបាទ នាងខ្ញុំ ពុំមានប្រវត្តិប្រព្រឹត្តបទល្មើសទាក់ទងជាមួយបទល្មើសណាមួយខាងលើចំពោះកុមារទេ។

ហត្ថលេខា៖________________________________ កាលបរិច្ឆេទ___________________

ព្រះនាម/ឈ្មោះ ________________________________________

# ឧបសម្ព័ន្ធ ២៖ យន្តការរាយការណ៍ករណី



## ឧបសម្ព័ន្ធ ៣៖ ទម្រង់រាយការណ៍ករណី

**ទម្រង់រាយការណ៍ករណីអំពើហិង្សា ឬការរំលោភបំពានលើកុមារ**

**លេខកូដករណី៖** ……………..

ឈ្មោះវត្ត និងអាសយដ្ឋាន៖

……………………………………………………………………………………………

រាយការណ៍ដោយ៖ ព្រះសង្ឃ ☐ គ្រហស្ថ ☐ មនុស្សពេញវ័យ ☐ កុមារ ☐ សមាជិកសហគមន៍ ☐

ព័ត៌មានបន្ថែម ……………………………………………….

ជនដែលសង្ស័យថាជាជនរងគ្រោះ ព្រះសង្ឃ ☐ មិនមែនសង្ឃ ☐ ចំនួនជនរងគ្រោះ ………

អាយុ……..

ជនល្មើសដែលត្រូវសង្ស័យ ព្រះសង្ឃ ☐ មិនមែនសង្ឃ ☐ មនុស្សពេញវ័យ ☐ កុមារ ☐ សមាជិកសហគមន៍☐

**ព័ត៌មានទាក់ទងករណី**

១. ចោទពីបទអ្វី? ហិង្សាផ្លូវកាយ ☐ ហិង្សាផ្លូវចិត្ត ☐ ហិង្សាផ្លូវភេទ ☐ ផ្សេងៗ(សូមបញ្ជាក់) ☐……

សូមសង្ខេបហេតុការណ៍ រួមទាំងកាលបរិច្ឆេទនិងទីតាំងនៃព្រឹត្តិការណ៍ដែលបានលើកឡើងនោះ។ល។

……………………………………………………………………………………………………………

……………………………………………………………………………………………………………

២. អំពីកុមារដែលសង្ស័យថាជាជនរងគ្រោះ

- ឈ្មោះ……………………………ភេទ………….. អាយុ……………..សញ្ជាតិ……………..
- ឈ្មោះ……………………………ភេទ………….. អាយុ……………..សញ្ជាតិ……………..

៣. តើបានដឹងអ្វីខ្លះអំពីជនល្មើសដែលត្រូវបានសង្ស័យ? សូមផ្តល់ព័ត៌មានអ្វីដែលមាន។

- ឈ្មោះ……………………………ភេទ………….. អាយុ……………..សញ្ជាតិ……………..

**ព័ត៌មានអំពីសេវាដែលបានផ្តល់ និងវិធានការចំពោះជនសង្ស័យ**

**៤. តើវត្តបានផ្តល់សេវាអ្វីខ្លះដល់កុមារជនរងគ្រោះ?**

ប្រឹក្សាយោបល់ ☐ បញ្ជូនទៅសេវាសុខភាព ☐ បញ្ជូនទៅអង្គការ ☐ បញ្ជូនទៅសង្គមកិច្ចស្រុក ☐

បញ្ជូនទៅសង្គមកិច្ចខេត្ត ☐ គ.ក.ស.ក. ☐ សេវាផ្សេង (សូមបញ្ជាក់ ☐……… ………………………………
កាលបរិច្ឆេទបញ្ជូន…………………………..

**៥. តើសកម្មភាពអ្វីខ្លះដែលត្រូវបានធ្វើឡើងចំពោះជនសង្ស័យជាជនល្មើស?**

បញ្ជូនទៅអាជ្ញាធរមូលដ្ឋាន ☐ បញ្ជូនទៅនគរបាល ☐ រាយការណ៍ទៅព្រះអនុគណ ☐
កាលបរិច្ឆេទបញ្ជូន…………………………..

**៦. តើព្រះចៅអធិការវត្តស្នើឡើងទៅអនុគណស្រុកចំពោះជនល្មើសជាប់សង្ស័យដែលជាព្រះសង្ឃ?**

អប់រំវិន័យធម៌ ☐ ចាត់វិធានការឱ្យចាកសិក្ខាបទ ☐ បញ្ជូនអាជ្ញាធរមូលដ្ឋាន ☐ បញ្ជូនទៅនគរបាល ☐ ផ្សេងៗ(សូមបញ្ជាក់) ☐……………………..

**៧. ព័ត៌មានបន្ថែម** ប្រសិនបើមាន

…………………………………………………………………………………………..

……………………………………………………………………………………………………………………

ថ្ងៃទី……………..ខែ……………..ឆ្នាំ…………..

ហត្ថលេខាអ្នកធ្វើរបាយការណ៍

ព្រះនាម ឬឈ្មោះ និងលេខទូរសព្ទទំនាក់ទំនង

ថ្ងៃទី……………..ខែ……………..ឆ្នាំ…………..

ហត្ថលេខាព្រះចៅអធិការ

ថ្ងៃទី……………..ខែ……………..ឆ្នាំ…………..

**សកម្មភាពដែលត្រូវបានដាក់ស្នើឡើងដោយវត្ត គឺត្រូវបាន៖**

☐ ឯកភាព ☐ មិនឯកភាព ☐ត្រូវការព័ត៌មានបន្ថែម……………..

**ព្រះនាម និងហត្ថលេខាព្រះអនុគណ**

**ចម្លងប្រគេន និងជូន៖**

☐ ព្រះមេគណ

☐ ប្រធានការិយាល័យធម្មការ និងសាសនា

☐ ប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក

## ឧបសម្ព័ន្ធ ៤៖ ទម្រង់របាយការណ៍លទ្ធផលកម្មវិធីវត្តសុខុមាលភាពកុមារ

ឈ្មោះវត្ត………. ……………….របាយការណ៍ត្រីមាសទី……………….…………..ឆ្នាំ……………………..

របាយការណ៍ប្រគេនព្រះអនុគណស្រុក…….

**១. បច្ចុប្បន្នភាពចំនួនមនុស្សក្នុងវត្ត**

- ចំនួនព្រះសង្ឃ…………….. អង្គ ចំនួនគ្រហស្ថ……………….នាក់ (ប្រុស…….នាក់; ស្រី…………..នាក់)
- ចំនួនអ្នកចុះហត្ថលេខាលើក្រមសីលធម៌ការពារសុវត្ថិភាពកុមារតាមវត្ត……………..នាក់

**២. កិច្ចប្រជុំ និងពិធីបុណ្យនានាដែលបានបញ្ជ្រាប ឬផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីកិច្ចការពារកុមារ និងគោលនយោបាយវត្តសុវត្ថិភាពកុមារ** (សូមសង្ខេបសកម្មភាពដែលបានធ្វើ)…………….........………………………………………………………………………………………………..

| កិច្ចប្រជុំ/ពិធីបុណ្យ/ កម្មវិធី | ចំនួនដង | ចំនួនព្រះសង្ឃចូលរួម | | | ចំនួនគ្រហស្ថ | | | | | អ្នកចូលរួមសរុបទាំងអស់ |
|---|---|---|---|---|---|---|---|---|---|---|
| | | ក្រោម ១៨ឆ្នាំ | លើ ១៨ឆ្នាំ | សរុប | ក្រោម១៨ឆ្នាំ | | លើ១៨ឆ្នាំ | | សរុប | |
| | | | | | ស្រី | ប្រុស | ស្រី | ប្រុស | | |
| នៅវត្ត | | | | | | | | | | |
| នៅសហគមន៍ | | | | | | | | | | |

| ចំនួនកុមាររងគ្រោះ | | ប្រភេទនៃការបំពាន* | សេវាបានផ្តល់** | ចំនួនជនសង្ស័យជាជនល្មើស | | |
|---|---|---|---|---|---|---|
| | | | | ព្រះសង្ឃ | គ្រហស្ថ | វិធានការណ៍ *** |
| កុមារា | | | | | | |
| កុមារី | | | | | | |

**៣. ចំនួនករណីរំលោភបំពានលើកុមារដែលបានរាយការណ៍ និងមានវិធានការណ៍ឆ្លើយតប**

***សំគាល់***៖សូមជ្រើសរើសយកប្រភេទនៃការបំពាន សេវាបានផ្តល់ វិធានការណ៍ខាងក្រោម៖

*ប្រភេទនៃការបំពាន៖ ហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ផ្សេងៗ……………………..

**សេវាបានផ្តល់៖ បញ្ជូនទៅសេវាសុខភាព NGO សង្គមកិច្ចស្រុក មន្ទីរសង្គមកិច្ច គ.ក.ស.ក. ប្រឹក្សាយោបល់ផ្សេងៗ…

***វិធានការណ៍៖ បញ្ជូនទៅអាជ្ញាធរមូលដ្ឋាន រាយការណ៍ទៅអនុគណចាត់វិធានការឱ្យសឹក បញ្ជូនទៅនគរបាលយុត្តិធម៌ផ្សេងៗ…

ថ្ងៃ……….ខែ……………..ឆ្នាំ……….......

ហត្ថលេខា អ្នកធ្វើរបាយការណ៍

ថ្ងៃ……….ខែ……………..ឆ្នាំ……….......

ហត្ថលេខា ព្រះចៅអធិការ

## ឧបសម្ព័ន្ធ ៥៖ តារាងតក្កភាពកម្មវិធី

| គោលបំណង/លទ្ធផលរំពឹងទុក | សូចនាករការអនុវត្ត | មធ្យោបាយផ្ទៀងផ្ទាត់ | ហានិភ័យ/ការសន្មត |
|---|---|---|---|
| ១. វត្តអារាមកាន់តែមានសុវត្ថិភាពសម្រាប់កុមារា កុមារី និងក្មេងជំទង់ (រួមទាំងក្មេងវត្ត) រួចផុតពីអំពើហិង្សា និងការរំលោភបំពាន | កុមារ និងមនុស្សពេញវ័យ រួមទាំងព្រះសង្ឃ សាមណេរ (នេន) និងគ្រហស្ថ នៅក្នុងវត្តមានចំណេះដឹងអំពីទម្រង់ផ្សេងៗនៃការរំលោភបំពាន និងអំពើហិង្សាលើកុមារ | FGDs និង ការសិក្សា KAP (មុន និងក្រោយកម្មវិធី) ជាមួយកុមារ និងមនុស្សពេញវ័យនៅក្នុងវត្តធ្វើឡើងដាច់ដោយឡែកពីគ្នា | អ្នកដឹកនាំសាសនាបង្ហាញឆន្ទៈក្នុងការអនុវត្តកម្មវិធី រួមទាំងការគាំទ្រការបណ្តុះបណ្តាល |
| | ចំនួន (ឬ %) នៃមនុស្សពេញវ័យរស់នៅក្នុង ឬមានទំនាក់ទំនងជាមួយវត្តបានចុះហត្ថលេខាលើក្រមសីលធម៌ | ការចងក្រងជាឯកសារ៖ របាយការណ៍របស់វត្តអារាម | ជនបង្គោលការពារសុវត្ថិភាពកុមារ ត្រូវបានចាត់តាំងឱ្យមានសកម្មភាពក្នុងការងារ |
| | កុមារ និងមនុស្សពេញវ័យរួមទាំងព្រះសង្ឃ សាមណេរ និងគ្រហស្ថបានដឹង និងយល់អំពីគោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម | FGDs ជាមួយកុមារ និងមនុស្សពេញវ័យនៅក្នុងវត្តដាច់ដោយឡែកពីគ្នា<br>FGDs ជាមួយ DoCR ថ្នាក់ស្រុក និងចៅអធិការវត្ត | គោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាមត្រូវបានទទួលយកដោយថ្នាក់ដឹកនាំជាន់ខ្ពស់ពុទ្ធសាសនា<br>ជនបង្គោលការពារសុវត្ថិភាពកុមារ ត្រូវបានចាត់តាំងឱ្យមានសកម្មភាពក្នុងការងារ |
| | ការដាក់ទណ្ឌកម្មផ្នែករាងកាយលើកុមារថយចុះ | FGDs | |
| | ចំនួនវត្តអារាមដែលរក្សាកំណត់ត្រាអំពីកុមារដែលស្នាក់នៅទាំងអស់ | កំណត់ត្រារបស់វត្តអារាម | វត្តអារាមមានសមត្ថភាព និងប្រព័ន្ធដើម្បីរក្សាកំណត់ត្រា |
| ២. ប្រព័ន្ធដើម្បីរាយការណ៍ និងឆ្លើយតបចំពោះករណីសង្ស័យការរំលោភបំពាន ត្រូវបានបង្កើតឱ្យមាននៅក្នុង<br>វត្តអារាម | ចំនួនវត្តអារាមដែលដាក់តាំងបង្ហាញក្រាហ្វិចលំហូរនៃការរាយការណ៍ | ការចុះទស្សនកិច្ចពិនិត្យតាមដាន | មានផ្ទាំងបដាអំពីក្រាហ្វិចលំហូរនៃការរាយការណ៍ជូនចំពោះវត្តដែលចូលរួមទាំងអស់ |
| | ចំនួនវត្តដែលមានសៀវភៅបញ្ជីអាសយដ្ឋានរបស់អ្នកផ្តល់សេវាផ្នែករដ្ឋាភិបាល និង | ការចុះទស្សនកិច្ចពិនិត្យតាមដាន | ជនបង្គោលការពារសុវត្ថិភាពកុមារ បានទទួលការគាំទ្រពីចៅអធិការ ព្រះ |

| គោលបំណង/លទ្ធផលរំពឹងទុក | សូចនាករការអនុវត្ត | មធ្យោបាយផ្ទៀងផ្ទាត់ | ហានិភ័យ/ការសន្មត |
|---|---|---|---|
| | មិនមែនរដ្ឋាភិបាលនៅក្នុងឃុំ & ស្រុក ដោយមានព័ត៌មានសម្រាប់ទំនាក់ទំនង | | សង្ឃជាន់ខ្ពស់ថ្នាក់ស្រុក និងអ្នកផ្តល់សេវាក្នុងការប្រមូលព័ត៌មាន |
| | ចំនួនកង្វល់ស្តីពីការការពារកុមារដែលត្រូវបានរាយការណ៍ | ការរាយការណ៍អំពីករណី & របាយការណ៍វឌ្ឍនភាព | មានទម្រង់សម្រាប់ការរាយការណ៍ករណី, ជនបង្គោលការពារសុវត្ថិភាពកុមារ មានពេល និងឆន្ទៈអនុវត្តភារកិច្ចរបស់ខ្លួន មនុស្សពេញវ័យ និងកុមារមានអារម្មណ៍ងាយស្រួលក្នុងការរាយការណ៍ |
| | ចំនួនករណីដែលត្រូវបានតាមដានបន្តភ្លាមៗ និងសកម្មភាពសមស្របត្រូវបានធ្វើឡើង | ការចងក្រងជាឯកសារៈ របាយការណ៍ករណី និងរបាយការណ៍បញ្ជូនពីអ្នកផ្តល់សេវាក្នុងមូលដ្ឋាន (ឧ. សុខាភិបាល DoSVY NGOs នគរបាល) FGDs ជាមួយកុមារ និងមនុស្សពេញវ័យនៅក្នុងវត្ត និងជាមួយអាជ្ញាធរមូលដ្ឋាន | មានទម្រង់សម្រាប់ការរាយការណ៍ករណី, ជនបង្គោលការពារសុវត្ថិភាពកុមារ មានពេលវេលា និងឆន្ទៈអនុវត្តភារកិច្ចរបស់ខ្លួនដំណើរការបានទទួលការគាំទ្រពីព្រះចៅអធិការ និងព្រះសង្ឃជាន់ខ្ពស់នៅក្នុងស្រុក |
| ៣.ពង្រឹងសមត្ថភាពព្រះសង្ឃក្នុងការតស៊ូមតិលើកកម្ពស់ការយល់ដឹង និងផ្តល់ប្រឹក្សាយោបល់ក្នុងសហគមន៍ ដើម្បីទប់ស្កាត់អំពើហិង្សាលើក្មេងស្រី ក្មេងប្រុស និងមនុស្សវ័យជំទង់ និងដើម្បីជាប្រយោជន៍ក្នុងការគាំទ្រកុមារឱ្យរស់នៅក្នុងគ្រួសារ | ចំនួនព្រះសង្ឃបានទទួលការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ ទម្រង់ និងផលវិបាកនៃអំពើហិង្សា និងការរំលោភបំពានកុមារ អត្ថប្រយោជន៍នៃការឱ្យកុមាររស់នៅជាមួយគ្រួសារ និង គោលនយោបាយការពារសុវត្ថិភាពកុមាររបស់វត្តអារាម | ការចងក្រងជាឯកសារ/របាយការណ៍វឌ្ឍនភាព | ក្រុមការងារថ្នាក់ជាតិទទួលបន្ទុកការបណ្តុះបណ្តាលត្រូវបានបង្កើតឡើង បានទទួលការបណ្តុះបណ្តាល និងការគាំទ្រដើម្បីអនុវត្តការបណ្តុះបណ្តាល |
| | ចំនួនសកម្មភាព/ព្រឹត្តិការណ៍ដែលត្រូវបានអនុវត្តដោយវត្តអារាម ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ | ការចងក្រងជាឯកសារ/របាយការណ៍វឌ្ឍនភាព FGDs ក្នុងសហគមន៍ | សមត្ថភាព និងឆន្ទៈរបស់វត្តអារាមក្នុងការចងក្រងជាឯកសារអំពីព្រឹត្តិការណ៍ និងសកម្មភាព។ |

| គោលបំណង/លទ្ធផលរំពឹងទុក | សូចនាករការអនុវត្ត | មធ្យោបាយផ្ទៀងផ្ទាត់ | ហានិភ័យ/ការសន្មត |
|---|---|---|---|
| | | | មានមូលនិធិ |
| | ចំនួនវត្តអារាមដែលត្រូវបានតំណាងនៅក្នុងកិច្ចប្រជុំជាប្រចាំថ្នាក់មូលដ្ឋាន ឧ. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ CCWC | FGDs ជាមួយមន្ត្រីថ្នាក់មូលដ្ឋាន កំណត់ហេតុកិច្ចប្រជុំ | កិច្ចសហការរវាងវត្តអារាម និងអាជ្ញាធរមូលដ្ឋាន |
| | សហគមន៍មានការយល់ដឹងកាន់តែច្រើនឡើងអំពីផលវិបាកនៃការរំលោភបំពានលើកុមារ និងការដាក់ទណ្ឌកម្មផ្នែករាងកាយមកលើការអភិវឌ្ឍរបស់កុមារ | FGDs និង ការសិក្សា KAP (មុននិងក្រោយកម្មវិធី) នៅក្នុងសហគមន៍ | ឆន្ទៈរបស់សមាជិកសហគមន៍ក្នុងការចូលរួមសារមានភាពច្បាស់លាស់ |

## ឧបសម្ព័ន្ធ ៦៖ ផែនការអនុវត្តកម្មវិធីរយៈពេល ៣ឆ្នាំ

| ល.រ. | គោលបំណង | ឆ្នាំទី ១ | | | | ឆ្នាំទី ២ | | | | ឆ្នាំទី ៣ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១. ធ្វើឱ្យវត្តអារាម និងសហគមន៍កាន់តែមានសុវត្ថិភាពសម្រាប់កុមារា កុមារី និងមនុស្សវ័យជំទង់រួចផុតពីអំពើហិង្សា និងការរំលោភបំពាន | | | | | | | | | | | | | |
| ២. បង្កើតប្រព័ន្ធសព្វជ្រុងជ្រោយមួយសម្រាប់ការរាយការណ៍ និងការឆ្លើយតបចំពោះករណីសង្ស័យការរំលោភបំពាននៅក្នុងវត្តអារាម | | | | | | | | | | | | | |
| ៣. ពង្រឹងសមត្ថភាពព្រះសង្ឃក្នុងធ្វើការតស៊ូមតិ លើកកម្ពស់ការយល់ដឹង និងការប្រឹក្សាយោបល់ជាមួយសហគមន៍ដើម្បីទប់ស្កាត់អំពើហិង្សា និង ការរំលោភបំពានលើក្មេងស្រី ក្មេងប្រុស និងមនុស្សវ័យជំទង់ និងដើម្បីផ្តល់ការគាំទ្រកុមារក្នុងគ្រួសារ។ | | | | | | | | | | | | | |
| **ធាតុចេញទី ១៖ គោលនយោបាយការពារសុវត្ថិភាពកុមារត្រូវបានអនុម័តជាផ្លូវការដោយ គណៈសង្ឃនាយក និងរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា** | | | | | | | | | | | | | |
| ***សកម្មភាពស្នូល*** | | | | | | | | | | | | | |
| ១.១ | សិក្ខាសាលាពិគ្រោះយោបល់លើក ដើម្បីពិនិត្យមើលកម្មវិធីទូទៅ រួមទាំងគោលនយោបាយវត្តសុវត្ថិភាពកុមារត្រូវបានរៀបចំឡើង | x | | | | | | | | | | | |
| ១.២ | គោលនយោបាយ និងផែនការអនុវត្តត្រូវបានព្រមព្រៀងគ្នាតាមរយៈការពិគ្រោះយោបល់ក្រោយសិក្ខាសាលា | x | x | | | | | x | | | | x | |
| ១.៣ | ការប្រកាសដាក់ឱ្យអនុវត្តកម្មវិធីវត្តសង្គហកុមារនៅថ្នាក់ជាតិ | | | x | | | | | | | | | |
| **ធាតុចេញទី ២៖ យន្តការមានលក្ខណៈកុមារមេត្រី និងឆ្លើយតប ត្រូវបានបង្កើតឡើងដើម្បី រាយការណ៍ និងតាមដានបន្តលើករណីការរំលោភបំពាននៅតាមវត្តអារាម** * | | | | | | | | | | | | | |
| ***សកម្មភាពស្នូល*** | | | | | | | | | | | | | |
| ២.១ | ចេញប្រកាសស្តីពីយន្តការរាយការណ៍ | | | x | | | | | | | | | |
| ២.២ | វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេស ស្តីពីគោលនយោបាយវត្តសុវត្ថិភាពកុមារ | | | | x | | | | | | | | |
| **ធាតុចេញទី ៣៖ ផែនការសម្រាប់ការចាប់ផ្តើមអនុវត្តត្រូវបានបង្កើតឡើង** | | | | | | | | | | | | | |
| ***សកម្មភាពស្នូល*** | | | | | | | | | | | | | |

| ល.រ. | គោលបំណង | ឆ្នាំទី ១ | | | | ឆ្នាំទី ២ | | | | ឆ្នាំទី ៣ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ៣.១ | ផែនការសម្រាប់ការអនុវត្តគោលនយោបាយការពារសុវត្ថិភាពកុមារតាមវត្តអារាម ត្រូវបានបង្កើតឡើង និងព្រមព្រៀងគ្នា និងអនុវត្ត | | x | x | | | | | | | | | |
| ៣.២ | ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍រវាងវត្តក្នុងប្រទេស និងជាមួយអន្តរជាតិ | | | | x | x | | | x | x | | | X |
| ៣.៣ | ការវាយតម្លៃរយៈពេលមួយឆ្នាំនៅលើវឌ្ឍនភាព ការប្រគល់វិញ្ញាបនបត្រទទួលស្គាល់ជាវត្តអារាមមានសុវត្ថិភាពសម្រាប់កុមារ (វត្តសង្គហកុមារ) | | | | | x | x | | | | | | |
| **ធាតុចេញទី ៤៖ វត្តនីមួយៗមានជនបង្គោលការពារសុវត្ថិភាពកុមារ** | | | | | | | | | | | | | |
| ***សកម្មភាពសូនាករ*** | | | | | | | | | | | | | |
| ៤.១ | ជនបង្គោលការពារសុវត្ថិភាពកុមារតាមវត្តអារាមត្រូវបានចាត់តាំង | x | | | | x | | | | x | | | |
| ៤.២ | ជនបង្គោលការពារសុវត្ថិភាពកុមារតាមវត្តអារាមបានទទួលការបណ្តុះបណ្តាល | | x | x | x | x | X | x | x | x | x | x | X |
| **ធាតុចេញទី ៥៖ កម្មវិធីសកម្មភាពនៅតាមវត្តអារាម និងការបណ្តុះបណ្តាលដល់សហគមន៍សម្រាប់ព្រះសង្ឃដើម្បីធ្វើការតស៊ូមតិ និងការយល់ដឹងក្នុងបំណងទប់ស្កាត់អំពើហិង្សាលើកុមារ និងការបំបែកចេញពីគ្រួសារដោយមិនចាំបាច់** | | | | | | | | | | | | | |
| ***សកម្មភាពសូនាករ*** | | | | | | | | | | | | | |
| ៥.១ | ការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ក្រុមបណ្តុះបណ្តាលថ្នាក់ជាតិ | | x | | | | X | | | | x | | |
| ៥.២ | ជ្រើសរើសវត្តសម្រាប់ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ | | | x | | | | x | | | | x | |
| **ធាតុចេញទី ៦៖ កម្មវិធីសិក្សាសម្រាប់ការលើកកម្ពស់ការយល់ដឹងត្រូវបានបង្កើតឡើង និងបកប្រែជាភាសាខ្មែរ** | | | | | | | | | | | | | |
| ***សកម្មភាពសូនាករ*** | | | | | | | | | | | | | |
| ៦.១ | ការបកប្រែសម្ភារៈទាំងអស់ | | x | | | | X | | | | x | | |
| ៦.២ | ការវាយតម្លៃនៅពេលបញ្ចប់គម្រោង | | | | | | | | | | | x | |

# ឧបសម្ព័ន្ធ ៧៖ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការផ្ដល់វិញ្ញាបនបត្រ និងមេដាយសម្រាប់វត្តសន្តហកុមារ

## ការផ្ដល់រង្វាន់សម្រាប់វត្ត

វិញ្ញាបនបត្រនិងរង្វាន់ នឹងត្រូវចេញឱ្យផ្អែកលើការជ្រើសតាំងឈ្មោះដោយក្រុម ឬសហគមន៍ណាមួយឬការដាក់ពាក្យបង្ហាញចំណាប់អារម្មណ៍ពីព្រះចៅអធិការវត្ត និងមានភស្តុតាងបញ្ជាក់អំពីលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម៖

- ចៅអធិការវត្តបង្ហាញការប្ដេជ្ញាចិត្ត ដើម្បីក្លាយជាវត្តការពារកុមារ
- បានអនុម័តទទួលយកគោលនយោបាយ ការពារសុវត្ថិភាពកុមារតាមវត្តអារាមមកប្រើប្រាស់ ហើយមនុស្សទាំងអស់ដែលកំពុងរស់នៅក្នុងវត្ត ឬមានទំនាក់ទំនងជាមួយវត្ត បានទទួលការបណ្ដុះបណ្ដាល (ឬកំពុងទទួលការបណ្ដុះបណ្ដាល) ស្ដីពីខ្លឹមសារគោលនយោបាយនេះ និងស្ដីពី: ការដាក់ពិន័យជាវិជ្ជមាន និងការអនុវត្តការចិញ្ចឹមបីបាច់កូន/ការថែទាំកុមារបែបវិជ្ជមាន
- មនុស្សពេញវ័យទាំងអស់ដែលកំពុងរស់នៅក្នុងវត្តឬមានទំនាក់ទំនងជាមួយវត្តបាន ចុះហត្ថលេខាលើក្រមសីលធម៌ និងយល់ខ្លឹមសារក្រមសីលធម៌ការរំលោភបំពាន
- ជនបង្គោលការពារសុវត្ថិភាពកុមារធ្វើសកម្មភាព ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារនិងផ្ដួចផ្ដើមដាក់របាយការណ៍ និងយន្តការបញ្ជូន ដើម្បីឆ្លើយតបចំពោះករណីសង្ស័យមានការរំលោភបំពាន
- វត្តមានផែនការសកម្មភាពការពារកុមារ ដោយក្នុងនោះរួមមានទាំងការបណ្ដុះបណ្ដាលបន្តសម្រាប់អ្នកមករស់នៅថ្មីនិងអ្នកស្ម័គ្រចិត្តហើយបានចូលរួមវិភាគទានមូលនិធិវត្តដើម្បីគាំទ្រកុមារប្រឈមហានិភ័យ
- ព្រះសង្ឃ អាចារ្យ និងដូនជីក្នុងវត្ត បានធ្វើសកម្មភាព ដើម្បីកែលម្អកិច្ចការពារកុមារនៅក្នុងសហគមន៍ឱ្យរួចផុតពីអំពើហិង្សាក្នុងការរំលោភបំពាន និងដើម្បីលើកកម្ពស់ការយល់ដឹងអំពីនិយាមសង្គមជាអវិជ្ជមាន ដែលជះឥទ្ធិពលជាអវិជ្ជមានដល់ការអភិវឌ្ឍរបស់កុមារ (ដូចជាការដាក់ទណ្ឌកម្មផ្នែករាងកាយ និងការបំបែកចេញពីគ្រួសារដោយមិនចាំបាច់)។

- វត្តសហការយ៉ាងសកម្មជាមួយក្រុមសហគមន៍ រួមទាំងក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការពារកុមារ និងគណៈកម្មាធិការទ្រទ្រង់សាលា ដើម្បីបង្កើនការការពារកុមារ។

**ការផ្ដល់រង្វាន់ចំពោះព្រះសង្ឃគំរូ**

ព្រះសង្ឃជាបុគ្គលអាចត្រូវបានជ្រើសតាំងឈ្មោះដោយមនុស្សនៅក្នុងសហគមន៍ព្រះចៅអធិការ ឬព្រះអនុគណ ឬព្រះមេគណ។ រៀងរាល់ឆ្នាំ ព្រះសង្ឃបីអង្គនឹងត្រូវបានជ្រើសរើសឱ្យទទួលវិញ្ញាបនបត្រ និងពានរង្វាន់ជាព្រះសង្ឃគំរូផ្នែកអហិង្សា និងកិច្ចការពារកុមារ ផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យដូចបានកំណត់ខាងក្រោម៖

- យល់ដឹងពីសិទ្ធិកុមារ
- យល់ដឹងអំពីគោលនយោបាយការពារកុមារតាមវត្តអារាម ក្រមសីលធម៌ និងយន្តការរាយការណ៍ចំពោះករណីសង្ស័យអំពើហិង្សា និងការរំលោភបំពានលើកុមារ
- តែងតែជាគំរូនៃអាកប្បកិរិយាអហិង្សាជាវិជ្ជមាន ចំពោះកុមារនៅក្នុងវត្ត និងនៅក្នុងសហគមន៍
- ផ្ដល់ដំបូន្មានដល់ព្រះសង្ឃដូចគ្នានិងគ្រហស្ថអំពីអាកប្បកិរិយាសមរម្យដែលត្រូវប្រព្រឹត្តចំពោះកុមារ
- តែងតែអប់រំកុមារ និងមនុស្សពេញវ័យក្នុងវត្តជាប្រចាំអំពីរបៀប ដើម្បីស្គាល់និងឆ្លើយតបចំពោះករណីសង្ស័យការរំលោភបំពាន
- បានបង្ហាញការប្ដេជ្ញាចិត្តខ្ពស់ ដើម្បីលើកកម្ពស់ការយល់ដឹងទាំងនៅក្នុងវត្ត និងក្នុងសហគមន៍ អំពីផលវិបាកនៃអំពើហិង្សា និងការរំលោភបំពានលើកុមារចំពោះការអភិវឌ្ឍរបស់កុមារ
- បានគាំទ្រយ៉ាងសកម្មឱ្យកុមាររស់នៅក្នុងគ្រួសារ ដើម្បីឱ្យពួកគេសម្រេចបានសិទ្ធិរបស់ខ្លួន

**អត្ថប្រយោជន៍នៃវិញ្ញាបនបត្រ និងពានរង្វាន់វត្តសង្គហកុមារ**

- ពានរង្វាន់ទទួលស្គាល់ជាវត្តកុមារសង្គហកុមារពី គណៈសង្ឃនាយកទាំងពីរ និងក្រសួងធម្មការ និងសាសនា
- ការទទួលស្គាល់តួនាទីរបស់វត្តក្នុងកិច្ចការពារកុមារ និងការមើលឃើញពីតម្លៃរបស់វត្ត របស់ព្រះពុទ្ធបរិស័ទនៅទូទាំងប្រទេសនិងទទួលបានការគាំទ្រ និងសហការពីស្ថាប័ននានាក៏ដូចជាប្រជាជនក្នុងសហគមន៍
- ក្លាយជាបណ្ដាញវត្តសុវត្ថិភាពកុមារនៅកម្ពុជា
- រួមចំណែកលើកតំកើងតម្លៃព្រះពុទ្ធសាសនា

- ព្រះសង្ឃនឹងក្លាយជាអ្នកផ្តល់ឱវាទដល់កុមារ ក៏ដូចជាអ្នកតស៊ូមតិសម្រាប់ សម្លេងកុមារ តាមផ្លូវព្រះធម៌
- បង្គលក្ខណៈឱ្យព្រះសង្ឃផ្តើមក្លាយជាអ្នកឧទ្ទេសនាមថ្នាក់ជាតិ និងអន្តរជាតិ

## ឧបសម្ព័ន្ធ ៨៖ ការគ្រប់គ្រងហានិភ័យ

| ល.រ. | ហានិភ័យ | យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ |
|---|---|---|
| ១ | បញ្ហាមូលនិធិដើម្បីអនុវត្តន៍៣ឆ្នាំដំបូង និងឆ្នាំបន្តទៀត | យុទ្ធសាស្ត្រអង្គាសមូលនិធិ និងប្រើប្រាស់ថវិការាជរដ្ឋាភិបាល |
| ២ | ព្រះសង្ឃនៅថ្នាក់ក្រោមអាចមានការពិបាកក្នុងការធ្វើការសម្រេចបានដោយសារជនសង្ស័យខ្លះមានឥទ្ធិពលខ្លាំង | ផ្តល់នូវការយល់ដឹង/ការបណ្តុះបណ្តាលដល់ព្រះសង្ឃថ្នាក់ជាតិអំពីសារៈសំខាន់នៃកិច្ចការពារកុមារ និងរៀបចំយន្តការដោះស្រាយករណីពីថ្នាក់ក្រោមជាតិដល់ថ្នាក់ជាតិ ក៏ដូចជាជំរុញឱ្យមានការគាំទ្រដោះស្រាយនូវរាល់ឧបសគ្គពីគណៈសង្ឃនាយក |
| ៣ | អំពើហិង្សាលើកុមារមិនត្រូវបានទទួលស្គាល់ជាបញ្ហានៅក្នុងបរិយាកាសវត្តអារាម | តាមរយៈការពិគ្រោះយោបល់ ការធ្វើបង្ហាត់បទបង្ហាញអំពីឧទាហរណ៍ពីបរិយាកាសសាសនាដទៃទៀត ពិភាក្សាលើករណី ដែលត្រូវបានរាយការណ៍ក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុង ប្រទេសកម្ពុជា ការពិភាក្សាអំពីភាពស្មាក់ស្មើរ (ពិនិត្យមើលលម្អិតអំពីបញ្ហា) |
| ៤ | ព្រះសង្ឃមានការមមាញឹកខ្លាំង ឬមិនមានឆន្ទៈចូលរួមក្នុងការបណ្តុះបណ្តាល | ប្រកាសចេញដោយសម្តេចសង្ឃនាយកឆ្លើយតប និងពិនិត្យលម្អិតលើភាពស្មាក់ស្មើរ |
| ៥ | ឆន្ទៈរបស់សហគមន៍ក្នុងការចូលរួមក្នុងការលើកកម្ពស់ការយល់ដឹង | ពន្យល់អំពីសកម្មភាព ឱ្យបានច្បាស់លាស់លើកកម្ពស់ការយល់ដឹងតាមរយៈពិធីបុណ្យសាសនា ដែលមានបច្ចុប្បន្នព្រះសង្ឃ/អ្នកដឹកនាំសាសនាពិភាក្សាអំពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ លើកទឹកចិត្តឱ្យមានការចូលរួមចំណែក |
| ៦ | ព្រះសង្ឃនៅអនុវត្តការដាក់ពិន័យក្នុងទម្រង់បែបប្រពៃណី ពោលគឺ ការដាក់ទណ្ឌកម្មផ្នែករាងកាយ | ការតស៊ូមតិ ការលើកទឹកចិត្តពីព្រះសង្ឃដទៃព្រះសង្ឃជាន់ខ្ពស់ដឹកនាំតាមរយៈការធ្វើជាឧទាហរណ៍គំរូប្រសិនបើចាំបាច់ត្រូវបានសកម្មភាពដាក់ទោសពិន័យ |

| | | |
|---|---|---|
| ៧ | ករណីមិនត្រូវបានរាយការណ៍ដល់ព្រះអនុគណ ព្រះមេគណ និងថ្នាក់ជាតិ ជនសង្ស័យរំលោភបំពានកុមារមិត្រូវបានបញ្ជូនទៅនគរបាល | ដោះស្រាយបញ្ហា ស្តីពីភាពមិនអនុលោមតាមច្បាប់នៅក្នុងវត្តអារាម ហើយនិងជាមួយអ្នកដឹកនាំថ្នាក់លើនៅពេលណាដែលចាំបាច់។ ធ្វើការពិនិត្យតាមដានជាប្រចាំ ដើម្បីធានានូវការអនុវត្តគោលនយោបាយ |
| ៨ | កុមារ ព្រះសង្ឃជាកុមារ ខ្វះការយល់ដឹងអំពីរបៀបដើម្បីរាយការណ៍ | ធានាឱ្យមានគោលនយោបាយក្នុងទម្រង់ងាយស្រួលយល់សម្រាប់កុមារ ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីកុមារក្នុងការបង្កើត និងផ្តល់យោបល់ត្រឡប់លើគោលនយោបាយនោះធានាឱ្យមានយន្តការរាយការណ៍ដែលកុមារអាចចូលទៅប្រើបាន និងមានលក្ខណៈងាយស្រួលប្រើប្រាស់សម្រាប់កុមារ |
| ៩ | ទស្សនៈខុសឆ្គងដែលយល់ឃើញថា យុទ្ធនាការដើម្បីកាត់បន្ថយកុមារនៅក្នុងការថែទាំជំនួស និងធ្វើឱ្យកាត់បន្ថយចំនួនសាមណេរនៅតាមវត្តអារាម | បកស្រាយឱ្យបានច្បាស់លាស់ជាមួយសង្ឃនិកាយថា គោលបំណងនៃកម្មវិធីនេះ គឺដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់សាមណេរ ដែលស្ថិតក្នុងការថែទាំតាមវត្តអារាម និងលើកម្ពស់ព្រះពុទ្ធសាសនាផលិតសៀវភៅរឿង វីដេអូ និងសម្ភារៈផ្សេងទៀត ដើម្បីលើកកម្ពស់ការយល់ដឹងពីតម្លៃ និងតួនាទីព្រះសង្ឃ |

## ក្រសួងធម្មការ និងសាសនា និងគណសង្ឃនាយកទាំងពីរគណៈ



អ្នកអាចបញ្ចប់អំពើហិង្សា! បញ្ចប់អំពើហិង្សា ដោយចាប់ផ្តើមពីអ្នក!
ព្រះសង្ឃជាតួអង្គគំរូក្នុងសហគមន៍

គាំទ្រដោយ រដ្ឋាភិបាលអូស្រ្តាលី តាមរយៈ UNICEF

Australian Aid

unicef
ដើម្បីកុមារគ្រប់រូប



វត្តប្រជុំជនី (វត្តក្រពើហា)

ព.ស ២៥៦២ គ.ស ២០១៨

បោះពុម្ពលើកទី២